

15th ANNIVERSARY

សិល្បៈខ្មែរអមតៈ

CAMBODIAN LIVING ARTS

# របាយការណ៍វាយតម្លៃលើសេចក្តីត្រូវការ ក្នុងការបណ្តុះបណ្តាលនិងជីវភាពការងារ ក្នុងវិស័យសិល្បៈទស្សនីយភាពខ្មែរ



ខែសីហា ឆ្នាំ២០១៣-ខែមិថុនា ឆ្នាំ២០១៤

ចេញផ្សាយ ខែសីហា ឆ្នាំ២០១៤









# ការលើកកម្ពស់សមត្ថភាពនិងវិជ្ជាជីវៈក្នុងសិល្បៈរបស់សិល្បករទស្សនីយភាពខ្មែរដើម្បីឲ្យមានសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងវិស័យវប្បធម៌

ចាប់ពីខែមីនា ឆ្នាំ២០១៤ ដល់ខែកុម្ភៈ ឆ្នាំ២០១៧ខាងមុខនេះ អង្គការចំនួន៦ ដែលមានរាយនាមខាងក្រោម នឹងរួមសហការគ្នាក្នុងគម្រោងការងារមួយដែលមានចំណងជើងថា៖ ការលើកកម្ពស់សមត្ថភាពនិងវិជ្ជាជីវៈក្នុងសិល្បៈរបស់សិល្បករទស្សនីយភាពខ្មែរដើម្បីឲ្យមានសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងវិស័យវប្បធម៌។

គម្រោងដ៏សំខាន់មួយនេះកំពុងត្រូវបានអនុវត្តដោយមានការគាំទ្រថវិកាពីសហភាពអឺរ៉ុប ក្រោមប្រធានបទ «ដាក់ទុនកសាងធនធានមនុស្ស» ស្របតាមទិសដៅការងារជាក់ស្តែងនៃ «ការទ្រទ្រង់វិស័យវប្បធម៌ជាទិសដៅអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនិងកំណើនសេដ្ឋកិច្ច»។

សហភាពអឺរ៉ុបជាសហគមន៍តំបន់មួយដែលមានរដ្ឋជាសមាជិកចំនួន២៧ ដែលបានធ្វើសមាហរណកម្មនូវចំណេះដឹង ធនធាន និងជោគវាសនារបស់ពួកគេ ។ ការរួមគ្នាជាធ្លុងមួយរយៈពេល៥០ឆ្នាំមកនេះ សហភាពអឺរ៉ុបសម្រេចបាននូវការកសាងសហគមន៍របស់ខ្លួន ឲ្យក្លាយទៅជាតំបន់ដែលមានស្ថិរភាព លទ្ធិប្រជាធិបតេយ្យនិងវឌ្ឍនប្រកបដោយចីរភាព ហើយនិងរក្សាបាននូវភាពចម្រុះគ្នានៃវប្បធម៌ ការយោគយល់ និងសេរីភាពបុគ្គល ។ សហភាពអឺរ៉ុបមានឆន្ទៈយ៉ាងម៉ឺងម៉ាត់ក្នុងចែករំលែកនូវសមិទ្ធផលនិងគុណតម្លៃទាំងឡាយរបស់ខ្លួន ជាមួយប្រទេសនិងប្រជាជាតិដ៏ទៃទៀតជុំវិញពិភពលោក។

គម្រោងនេះនឹងមានដាក់បញ្ចូលនូវកម្រងសកម្មភាពការងារ ដែលនឹងមានផ្តល់ផលប្រយោជន៍ដល់អង្គការ សមាគមដ៏ទៃផ្សេងៗទៀតក្រៅពីដៃគូគម្រោងដែលមានរាយនាម និងផ្តល់នូវផលវិជ្ជមានដល់សិល្បករនិងធុរជនសិល្បៈទូទៅ ក្នុងវិស័យសិល្បៈវប្បធម៌ទាំងមូល។ ផែនការសកម្មភាពមានដូចជា៖

- ផ្តួចផ្តើមឲ្យមានឱកាសរៀនសូត្របន្ថែមទៀតសម្រាប់សិល្បករនិងអ្នកបច្ចេកទេស
- ពង្រឹងនិងបង្កើននូវគុណភាពបណ្តុះបណ្តាលដែលកំពុងដំណើរការ
- ជម្រុញឲ្យមានបរិយាកាសវប្បធម៌មួយមានអំណោយផលដល់ការផ្សព្វផ្សាយសិល្បៈនិងការផលិត តាមរយៈការបណ្តុះបណ្តាលធនធានផ្សេងៗ និងហេដ្ឋារចនាសម្ពន្ធ
- អភិវឌ្ឍភាពជាអ្នកដឹកនាំក្នុងវិស័យសិល្បៈ
- ដឹកនាំនិងគាំទ្រឲ្យមាននូវគំនិតផ្តួចផ្តើមជាសហគ្រិនក្នុងវិស័យនេះ ដើម្បីពង្រីកភាពវិសាលភាពនិងគុណភាពសិល្បៈទស្សនីយភាពក្នុងទីផ្សា និងបង្កើនឲ្យមានតម្រូវការខ្ពស់

សន្ទង់មតិនេះ ប្រមែប្រមូលព័ត៌មាន វិភាគនិងសរុបទិន្នន័យ និងចេញផ្សាយដោយអង្គការសិល្បៈខ្មែរអមតៈ និងជាកត្តាលីករសំខាន់មួយក្នុងគម្រោងនេះ ហេតុដូច្នេះក៏ទទួលថវិកាមួយភាគពីសហភាពអឺរ៉ុបដើម្បីអាចដំណើរការបានដល់ត្រឹមនេះ។ លទ្ធផលដែលទទួលបានពីសន្ទង់នេះនឹងត្រូវដៃគូការងារទាំងឡាយយកទៅប្រើប្រាស់ដើម្បីធានាឲ្យបានថាសកម្មភាពការងារក្នុងប៉ុន្មានឆ្នាំខាងមុខរបស់ខ្លួនត្រូវចំគោលដៅ និងមានប្រសិទ្ធិភាពខ្ពស់។ ម៉្យាងទៀត លទ្ធផលនៃសន្ទង់នេះអាចដើរតួនាទីជាសូចនករក្នុងការត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពការងារថ្ងៃមុខ។

ប្រសិនបើមានចម្ងល់ផ្សេងៗអំពីសន្ទង់នេះ សូមមេត្តាទាក់ទងយកព័ត៌មានលម្អិតតាមសារអេឡិចត្រូនិច info@cambodianlivingarts.org ។ ប្រសិនលោកអ្នកមានចំណាប់អារម្មណ៍ស្វែងយល់បន្ថែម ឬចូលរួមក្នុងគម្រោងធំនៅថ្ងៃខាងមុខ សូមមេត្តាទាក់ទងទៅ performing.arts@phareps.org ។

# មាតិកា


**សេចក្តីសង្ខេប ........................................................ ២**

**វិធីសាស្ត្រសន្ទង់ .................................................... ៤**

- ទិសដៅ ........................................................ ៤
- និយមន័យនៃក្រុមគំរូឬក្រុមសំណាក ............................ ៤
- ដំណាក់កាលនៃសន្ទង់ ............................................ ៤
- ការបែងចែកក្រុមគំរូនិងកំណត់ចំណាំផ្សេងៗ ....................... ៥
- កំណត់ចំណាំបន្ថែម ............................................... ៥

**I - ទិដ្ឋភាពសង្គមទូទៅនៃវិស័យសិល្បៈខ្មែរ ............................ ៦**

- ១. ភេទ ........................................................... ៧
- ២. ក្រុមសំណាក២ក្រុមមានគោលបំណងតែ១ គឺការធ្វើឲ្យរស់ឡើងវិញនូវសិល្បៈខ្មែរ ........................................... ៧
- ៣. ក្រុមសំណាកមានទីលំនៅក្នុងទីក្រុងមានចំនួនភាគច្រើនដែលជាកត្តាកំណត់លើវិស័យទាំងមូល ............... ៨

**II - ស្ថានភាពសិក្សានិងការងារ៖ ក្រុមសំណាកសិល្បករកំពុងស្ថិតក្នុងដំណាក់កាលឈានទៅរកភាពអាជីព ............... ១០**

- ១. ក្របខណ្ឌការងារ ( ការសម្តែងជាការងារចម្បង ) ............ ១១
  - *ជំនាញចាំបាច់៖ ជំនាញប្រើប្រាស់កុំព្យូទ័រ ............................ ១២*
- ២. ការងារបង្ហាត់ ................................................... ១២
- ៣. ការហាត់និងការត្រៀមខ្លួនមុនពេលសម្តែង ...................... ១៣
  - *តម្រូវការសម្ភារៈ ................................................ ១៣*
  - *ទីកន្លែងហាត់សម ............................................... ១៣*
  - *សុខភាព ........................................................ ១៣*
  - *ជំនាញចាំបាច់៖ ជំនាញបច្ចេកទេសសិល្បៈ .......................... ១៤*
  - *ជំនាញចាំបាច់៖ ជំនាញបច្ចេកទេសទូទៅ ............................ ១៤*
- ៤. ការស្វែងយល់ពីយុទ្ធសាស្ត្រនិងបណ្តាញសិល្បៈ .............. ១៥
  - *ជំនាញចាំបាច់៖ យុទ្ធសាស្ត្រនិងបណ្តាញទំនាក់ទំនងទីផ្សារ ....... ១៥*
- ៥. ពេលវេលាសម្តែង ............................................... ១៦
  - *ជំនាញចាំបាច់៖ ជំនាញគ្រប់គ្រងការងារ ............................. ១៦*
- ៦. ទីកន្លែងសម្តែង ទស្សនិកជន និងការធ្វើដំណើរសម្តែង ..... ១៧
  - *ការភ័យខ្លាចក្នុងការធ្វើដំណើរ៖ ..................................... ១៧*
  - *ជំនាញចាំបាច់៖ ជំនាញភាសាបរទេស ................................ ១៧*

**III - ស្ថានភាពសេដ្ឋកិច្ច ................................................ ១៨**

- ១. ប្រាក់កំរៃសម្តែង ................................................ ១៩
  - *ជំនាញគ្រប់គ្រងថវិកា ........................................... ១៩*
- ២. ចំណូលប្រចាំខែ ................................................. ២០
- ៣. ស្ថានភាពការងារមិនមានស្ថេរភាព .............................. ២០
- ៤. ចំណូលបំពេញបន្ថែមនិងការគាំទ្រជីវភាពរស់នៅ ............ ២១
- ៥. ស្ថានភាពការងារវិភាគតាមការបែងចែកក្រុមផ្សេងៗទៀត .២៣
  - ក. សមភាពយេនឌ័រ (វិសមភាពនៃប្រាក់ចំណូល ........... ២៣
  - *សមភាពយេនឌ័រ ................................................ ២៣*
  - ខ. អ្នកមានពិការភាពក្នុងសិល្បៈទស្សនីយភាព ( គំនិតផ្តួចផ្តើមនិងការលើកទឹកចិត្តក្នុងសិល្បៈនៅមានការរើសអើង ) ..២៣
  - *ការរើសអើងចំពោះអ្នកដែលមានពិការភាព ......................... ២៤*
  - គ. ស្ថានភាពទីតាំងភូមិសាស្ត្រ( សក្តានុពលខ្ពស់នៃទីក្រុង )..... ២៤

**សេចក្តីសន្និដ្ឋាន .................................................... ២៦**

**សេចក្តីថ្លែងអំណរគុណ ............................................... ២៧**





សេចក្តីសង្ខេប

**២**



វិធីសាស្ត្រសន្ទង់

**៤**







ទិដ្ឋភាពសង្គមទូទៅ
នៃវិស័យសិល្បៈខ្មែរ

**៦**



ស្ថានភាព
សិក្សានិងការងារ

**១០**







ស្ថានភាពសេដ្ឋកិច្ច

**១៨**



សេចក្តីសន្និដ្ឋាន
សេចក្តីថ្លែងអំណរគុណ

**២៦-២៧**




# សេចក្តីសង្ខេប



ចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែឧសភា ឆ្នាំ២០១៤ អង្គការសិល្បៈខ្មែរអមតៈ បានធ្វើការស្ទង់មតិ សិល្បករខ្មែរចំនួន៣៨០រូប និងធុរជនសិល្បៈខ្មែរចំនួន៨៤រូប ដើម្បីរកទិន្នន័យក្នុងប្រធានបទផ្សេងៗពាក់ព័ន្ធនិងវិស័យសិល្បៈទស្សនីយភាពខ្មែរ ។



## សិល្បករជំនាន់ថ្មី

បន្ទាប់ពីរបបខ្មែរក្រហម សិល្បៈទស្សនីយភាពខ្មែរបាននិងកំពុងឆ្លងកាត់នូវការវិវត្តមួយគួរជាទីចាប់អារម្មណ៍។ សិល្បករខ្មែរភាគច្រើនបានបាត់បង់ជីវិតក្នុងរបបនោះ និងសិល្បករជំនាន់ថ្មីនាពេលបច្ចុប្បន្ននេះ ជាយុវជនដែលមានអាយុជាមធ្យម២៦ឆ្នាំ។ ក្នុងចំណោមនោះ ពួកគេចំនួនតែ៦៦ភាគរយប៉ុណ្ណោះដែលបានទទួលការហាត់រៀនត្រឹមត្រូវពីគ្រូសិល្បៈដែលមានជំនាញសិល្បៈពិតប្រាកដ។



## តួនាទីសំខាន់នៃអង្គការសង្គមស៊ីវិល

យោងតាមស្ថានភាពទូទៅនាពេលបច្ចុប្បន្ននេះ ជីវភាពសិល្បៈរបស់សិល្បករទាំងឡាយកំពុងអភិវឌ្ឍនិងមានលក្ខណៈជាប្រតិបត្តិសិល្បៈក្រៅប្រព័ន្ធនិងជាស្ថាប័នសិល្បៈដែលមានភាពទន់ខ្សោយ។ តួលេខបង្ហាញថា៖ សិល្បករចំនួនប្រមាន៤៩ភាគរយ មានការងារជាប្រចាំនៅស្ថាប័នមួយ និង៤២ភាគរយនៃសិល្បករដែលមានការងារប្រចាំទាំងនេះមានកិច្ចសន្យាការងារ។ អង្គការសមាគមក្រៅរដ្ឋាភិបាល ទទួលយកតួនាទីដ៏សំខាន់ក្នុងការទ្រទ្រង់ជីវភាពសិល្បៈ ពីព្រោះសិល្បករ២៧ភាគរយធ្លាប់មានការងារប្រចាំជាមួយអង្គការឬសមាគមក្រៅរដ្ឋាភិបាល។



## តម្រូវការការបណ្តុះបណ្តាលក្នុងជំនាញ

ធុរជនសិល្បៈភាគច្រើនមានកម្រិតវប្បធម៌ខ្ពស់ជាងសិល្បករ ដោយហេតុថា ធុរជនសិល្បៈប្រមាណ៥០ភាគរយមានបានរៀនចប់ថ្នាក់ឧត្តមសិក្សាមានបរិញ្ញាបត្រ ចំណែកឯសិល្បករមានតែ១៥ភាគរយប៉ុណ្ណោះ។ វិស័យសិល្បៈទស្សនីយភាពនេះ មានតម្រូវការឲ្យសិល្បករទទួលការអប់រំបន្ថែម និងត្រូវការធុរជនសិល្បៈដែលមានសមត្ថភាពបង្កបង្កើតនូវសកម្មភាពសិល្បៈដើម្បីការរីកចម្រើន។ ដំណើរការនេះតម្រូវឲ្យសិល្បកររៀនសូត្រនូវជំនាញបន្ថែមដែលអាចជួយដល់ជីវភាពសិល្បៈរបស់ពួកគេ។ បច្ចេកវិទ្យាកុំព្យូទ័រនិងអ៊ិនធើណិតមានសារប្រយោជន៍ក្នុងវិស័យនេះ ដើម្បីធ្វើឲ្យរលូននូវទំនាក់ទំនងរវាងសិល្បករការផ្សព្វផ្សាយអំពីស្នាដៃសិល្បៈរបស់ខ្លួន និងការពង្រឹងលទ្ធភាពក្នុងការសម្របសម្រួលចំណាត់ការទូទៅ។ សិល្បករមួយចំនួនមានចំណេះដឹងមូលដ្ឋានក្នុងការប្រើប្រាស់កុំព្យូទ័រ។ ជាមួយគ្នានេះដែរសិល្បករប្រមាណ៤៣ភាគរយប្រើប្រាស់អ៊ិនធើណិតយ៉ាងតិចណាស់ម្តងក្នុងមួយថ្ងៃ។ ទាំងអស់នេះ ជាសញ្ញាណវិជ្ជមានសម្រាប់កម្មវិធីបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពរបស់សិល្បករ។ រីឯធុរជនសិល្បៈវិញជំនាញក្នុងការប្រើប្រាស់កុំព្យូទ័រមានភាពប្រសើរជាងដែលពួកគេប្រមាណ៧០ភាគរយ អាចប្រើប្រាស់សារអេឡិចត្រូនិចនិង៤៤ភាគរយអាចប្រើប្រាស់កម្មវិធី Microsoft Word ។ កម្មវិធីបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពនឹងជួយពួកគេបានទទួលភាពជុះដាលក្នុងប្រសិទ្ធិភាពនិងផលិតភាពការងារ។







ការសម្តែងសិល្បៈជាប្រភពចំណូលចម្បងរបស់សិល្បករដែលសិល្បករប្រមាណ៨២ភាគរយពឹងផ្អែកលើប្រភពចំណូលនេះជាសំខាន់ក្នុងការរស់នៅ។ ភាគច្រើននៃចំនួនម៉ោងការងាររបស់សិល្បករត្រូវបានចំណាយទៅលើការរៀបចំត្រៀមសម្តែង។ សិល្បករ៦៦ភាគរយហាត់រៀនក្នុងថ្នាក់ជាផ្លូវការជាមធ្យមចំនួន៣,៥ដងក្នុងមួយសប្តាហ៍ ៦៦ភាគរយហាត់សមរួមគ្នាយ៉ាងតិចម្តងក្នុងមួយសប្តាហ៍និង៧០ភាគរយហាត់សមនិងបង្កើតស្នាដៃថ្មីដោយខ្លួនឯងយ៉ាងតិច២ដងក្នុងមួយសប្តាហ៍។ សិល្បករមួយចំនួនបញ្ជាក់ពីការលំបាកក្នុងការងារសិល្បៈរបស់ពួកគេគឺសម្ភារៈនិងឧបករណ៍សិល្បៈ និងទីកន្លែងហាត់សម ហើយពួកគេក៏ត្រូវការការហាត់រៀនបន្ថែម។

សិល្បករបំពេញការងារជាមធ្យមចំនួន២ម៉ោង៤៨នាទីក្នុង១សប្តាហ៍ ដោយមានការសម្តែងប្រចាំសប្តាហ៍ ដែលពួកគេអាចទទួលចំណូលសរុបចំនួន២១ដុល្លារអាមេរិច (ថ្លៃឈ្នួលការងារ ៧ដុល្លារអាមេរិចក្នុង១ម៉ោង)។ ទោះជាយ៉ាងនេះក្តី អត្រាប្រាក់ឈ្នួលការងារនេះអាចមានតួលេខខុសគ្នាអាស្រ័យលើជំនាញសិល្បៈនិងក្របខណ្ឌការងារផ្សេងៗគ្នា។ ជាឧទាហរណ៍សិល្បករសៀកភាគច្រើនមកពីអង្គការហ្វារពន្លឺសិល្បៈមានស្ថានភាពចំណូលខ្ពស់ជាងមធ្យមភាគចំណូលខាងលើ។ ពួកគេមានអត្រាថ្លៃឈ្នួលការងារស្មើនឹង១៤ដុល្លារអាមេរិចក្នុង១ម៉ោង ដោយសារតែការទទួលការបណ្តុះបណ្តាលកម្រិតអាជីពក្នុងជំនាញសិល្បៈនិងការសម្តែងមានគុណភាពទូទៅខ្ពស់។ បើក្រលេកមកមើលធុរជនសិល្បៈវិញ ៦៩ភាគរយនៃពួកគេមានការងារពេញម៉ោង ហើយពួកគេប្រមាណ៣៩ភាគរយធ្វើការងារជាក្រុមការងារបច្ចេកទេសឬជាអ្នកចាត់ការទូទៅសម្រាប់សិល្បករ។ ធុរជនសិល្បៈធ្វើការងារលើការសម្តែងចំនួន៦៤លើកក្នុងឆ្នាំ២០១៣ និងបានទទួលចំណូលក្នុងអត្រា៣៤ដុល្លារអាមេរិចក្នុង១ម៉ោង។

ក្រៅពីការបណ្តុះបណ្តាលក្នុងបច្ចេកទេសសិល្បៈកម្មវិធីបំប៉នបន្ថែមលើបច្ចេកទេសទូទៅក្នុងការចាត់ចែងផលិតកម្មដូចជាប្រព័ន្ធសម្លេងនិងពន្លឺមានសារៈសំខាន់ជួយឲ្យសិល្បករបានយល់ដឹងលើការរៀបចំការសម្តែងនិងការគ្រប់គ្រងដំណើរការសម្តែងឲ្យបានលក្ខណៈល្អប្រសើរ។ យោងលើរបាយការណ៍ទទួលបាន សិល្បករប្រមាណ៥០ភាគរយពុំមានចំណេះដឹងអំពីប្រព័ន្ធសម្លេងនិងពន្លឺទេ។ លើសពីនេះទៅទៀតរបាយការណ៍ក៏បានបង្ហាញថា ការចាត់ការទូទៅសម្រាប់សិល្បករជាតួនាទីចម្បងមួយកំណត់លើកម្រិតក្របខណ្ឌអាជីពក្នុងការងារពួកគេ។ មានសិល្បករមួយចំនួនដែលបានលើកក្នុងចម្លើយរបស់ពួកគេថាមានវិវាទផ្សេងៗនិងបញ្ហាមិនគោរពម៉ោងពេលការងារ ដូចជាការយឺតយ៉ាវក្នុងម៉ោងហាត់សមនិងការសម្តែងជាដើម។ កម្មវិធីបណ្តុះបណ្តាលផ្សេងៗអាចជួយដោះស្រាយបញ្ហានិងលើកកម្ពស់ឥរិយាបថអាជីពក្នុងការងារនេះបាន។

ចំណុចមួយទៀតដែលមានសក្តានុពលក្នុងការបង្កើនសមត្ថភាពអាជីពរបស់សិល្បករ គឺការផ្តោតទៅលើទំនាក់ទំនងជាបណ្តាញរវាងសិល្បករនិងសិល្បករ ដែលជួយឲ្យមានការសម្របសម្រួលមុខរបរនិងការងារទូទៅក្នុងអាជីពនេះបានប្រសើរជាងមុន។ ជាតឹកតាង សិល្បករប្រមាណ២៥ភាគរយជួយសម្តែងគ្នានិងផ្លាស់ប្តូរសិល្បករគ្នាទៅវិញទៅមកក្នុងការសម្តែង។ វិស័យសិល្បៈទស្សនីយភាពដែលជាកម្លាំងចលករសេដ្ឋកិច្ចមួយ អាចប្រើសក្តានុពលក្នុងវិស័យផ្សេងៗទៀត (ដូចជាវិស័យទេសចរណ៍ជាដើម) មកជម្រុញមុខរបរនិងការងារក្នុងវិស័យរបស់ខ្លួន។ សិល្បករ២៥ភាគរយមានឱកាសសម្តែងនៅតាមភោជនីយដ្ឋាន និង១០ភាគរយនៅតាមសណ្ឋាគារក្នុងរយៈពេល៦ខែចុងក្រោយនេះ។ វិស័យទេសចរណ៍ផ្តល់នូវឱកាសមុខរបរនិងការងារដ៏ប្រសើរមួយ ហើយសិល្បករប្រមាណ៩០ភាគរយមានឱកាសសម្តែងសម្រាប់ភ្ញៀវទេសចរណ៍ក្នុងឆ្នាំ២០១៣។ ទាក់ទងនឹងចំណុចនេះ សិល្បករ៨៦ភាគរយនិងធុរជនសិល្បៈ៨៩ភាគរយបានផ្តល់ចម្លើយថា ភាសាអង់គ្លេសជាតម្រូវការចាំបាច់មួយក្នុងជីវភាពសិល្បៈអាជីពរបស់ពួកគេ ហើយជាក់ស្តែងសិល្បករ៥០ភាគរយនិងធុរជនសិល្បៈ៣៧ភាគរយ មិនមានចំណេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់ក្នុងការងារអាជីពនេះទេ។ កម្មវិធីបណ្តុះបណ្តាលភាសាអង់គ្លេស មានសារៈសំខាន់និងចាំបាច់ ដោយហេតុថាសិល្បករចំនួន៥១ភាគរយធ្លាប់ធ្វើដំណើរសម្តែងនៅឯបរទេស ហើយពួកគេត្រូវការភាសាអង់គ្លេសក្នុងទំនាក់ទំនងអំពីទម្រង់សិល្បៈរបស់ខ្លួន។

ដោយយោងតាមស្ថានភាពសេដ្ឋកិច្ចរបស់សិល្បករ ការគណនាផ្សេងៗក្នុងសន្ទង់នេះបានស្រាយបំភ្លឺថា សិល្បកររកចំណូលជាមធ្យមបានចំនួន៩២ដុល្លារអាមេរិចក្នុង១ខែពីការសម្តែង។ ក្នុងចំណោមនោះ ពួកគេខ្លះបង្ហាត់សិល្បៈនិងរកចំណូលប្រចាំខែមធ្យមបានចំនួន៨០ដុល្លារអាមេរិច។ គួរបញ្ជាក់ផងដែរថា សិល្បករ៣៣ភាគរយមានការងារក្រៅពីសិល្បៈ ហើយទោះជាការងារក្រៅនេះនាំចំណូលបន្ថែមដល់ពួកគេក្តី សិល្បករ៥២ភាគរយនៅតែរកចំណូលប្រចាំខែបានតិចជាង១០០ដុល្លារអាមេរិចពីការងារទាំងក្នុងនិងក្រៅសិល្បៈ។ បើប្រៀបធៀបជាមួយធុរជនសិល្បៈ ពួកគេនោះមានស្ថានភាពប្រសើរជាង ដោយពួកគេរកចំណូលប្រចាំខែជាមធ្យមបានចំនួន២៧៤ដុល្លារអាមេរិច ។

ទន្ទឹមនិងនេះ កត្តាវិសមភាពមួយចំនួនមានផលប៉ះពាល់ នាំឲ្យវិស័យសិល្បៈពិបាកនឹងផ្តល់នូវស្ថានភាពសេដ្ឋកិច្ចសមរម្យមួយដល់សិល្បករ។ កត្តាទាំងនេះរួមមានភេទ ពិការភាព និងតំបន់រស់នៅ ។សិល្បការិនីត្រូវធ្វើការងារជាមធ្យម២០នាទីច្រើនជាងសិល្បករ (បុរស) ហើយត្រូវទទួលបានថ្លៃឈ្នួលម៉ោងតិចជាងបុរស២ដុល្លារអាមេរិចទៀត។ សិល្បការិនីរកចំណូលប្រចាំខែជាមធ្យមបាន៧៥ដុល្លារអាមេរិចពីការសម្តែង ចំណែកឯបុរសវិញរកបានរហូតដល់ទៅ១០១ដុល្លារ។ ចំណុចដូចគ្នានេះក៏មានក្នុងចំណោមធុរជនសិល្បៈដែរ ដែលស្ត្រីរកចំណូលប្រចាំខែជាមធ្យមបាន២០៤ដុល្លារអាមេរិច រីឯបុរសវិញរកបាន៣២៧ដុល្លារអាមេរិច។ ចំណុចមួយផ្សេងទៀត សិល្បករប្រមាណ៨ភាគរយមានពិការភាព ហើយពួកគេមួយចំនួនបានផ្តល់ចម្លើយអំពីការលំបាកក្នុងជីវភាពសិល្បៈ ដោយសារតែបញ្ហាដូចជាលទ្ធភាពទំនាក់ទំនងនិងការរើសអើងក្នុងសង្គម។ ចំណុចមួយចុងក្រោយ គឺសិល្បករដែលរស់នៅជនបទរកចំណូលប្រាក់ម៉ោងពីការសម្តែងចំនួន៥,៦ដុល្លារអាមេរិចក្នុង១ម៉ោង ធៀបនឹងសិល្បករនៅទីក្រុងទទួលបាន៧,៤ដុល្លារអាមេរិច។

# វិធីសាស្ត្រសន្ទង់



## ទិសដៅ

ទិសដៅចម្បងក្នុងការអនុវត្តសន្ទង់នេះមានដូចតទៅ៖

១. សិក្សាលើប្រាក់កំរៃនិងគោលនយោបាយការងារនៃសិល្បករនិងធុរជនដែលកំពុងធ្វើការក្នុងវិស័យសិល្បៈទស្សនីយភាពខ្មែរទូទាំងប្រទេស ។

២. សិក្សាទៅលើតម្រូវការបណ្តុះបណ្តាលបន្ថែមរបស់សិល្បករនិងធុរជនជាពិសេសទាក់ទិននិងជំនាញ ដែលជួយបង្កើនសកម្មភាពការងារក្នុងសិល្បៈអាជីពរបស់ពួកគេ ។

៣. សិក្សាទៅលើកត្តាផ្សេងៗដែលជាបញ្ហាប្រឈមដែលសិល្បករនិងធុរជនជួបការលំបាកក្នុងការបង្កើនសកម្មភាពការងារក្នុងសិល្បៈ ។

ដើម្បីសម្រេចបាននូវទិសដៅទាំងនេះ យើងយកវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណ ដោយប្រើប្រាស់កម្រងសំណួរ ដើម្បីទទួលបាននូវព័ត៌មានទូលំទូលាយអំពីវិស័យសិល្បៈទស្សនីយភាពនេះ និងអំពីស្ថានភាពដោយឡែករៀងៗខ្លួនរបស់សិល្បករ ។

## និយមន័យនៃក្រុមគំរូឬក្រុមសំណាក

ដើម្បីបង្កើតបាននូវសន្ទង់មួយដែលមានភាពច្បាសលាស់និងពាក់ព័ន្ធ យើងដាក់ដែនកំណត់នៃការសិក្សារបស់យើង ដោយផ្តោតទៅលើទាំង២ក្រុមខាងក្រោម៖

- **សិល្បករអាជីព៖** ជាសិល្បករខ្មែរដែលកំពុងធ្វើការក្នុងវិស័យសិល្បៈទស្សនីយភាពដែលរកទទួលទានពីជំនាញសិល្បៈរបស់ខ្លួនហើយបានសម្តែងយ៉ាងតិចម្តងក្នុងរយៈពេល៦ខែចុងក្រោយ (គិតក្នុងកំឡុងពេលចែកចាយនិងប្រមូលសន្ទង់នេះ[១])។ ការប្រើប្រាស់ពាក្យថា «សិល្បករ» ក្នុងសន្ទង់នេះ គឺមានន័យដូចគ្នាទៅនឹងនិយមន័យមួយនេះដែរ។
- **ធុរជនសិល្បៈ៖** ជាធុរជនខ្មែរដែលធ្វើការងារក្នុងវិស័យសិល្បៈ តែមិនមែនជាសិល្បករ(ឧទាហរណ៍៖អ្នកបច្ចេកទេសអ្នកចាត់ការទូទៅសម្រាប់សិល្បករ។ល។) និងទទួលចំណូលពីការងារនេះក្នុងរយៈពេល៦ខែចុងក្រោយ (គិតក្នុងកំឡុងពេលចែកចាយនិងប្រមូលសន្ទង់នេះ)។

ក្រុមទាំង២ខាងលើនេះ គឺជាក្រុមគំរូក្នុងសន្ទង់នេះ ហើយក្រុមនីមួយៗមានកម្រងសំណួរផ្សេងគ្នា។ ជាមួយគ្នានេះផងដែរដោយសារនឹងពេលវេលានិងមធ្យោបាយសម្រាប់សន្ទង់នេះ យើងបានសម្រេចជ្រើសរើសខេត្តចំនួន៦នៃព្រះរាជាណាចក្រកម្ពុជាមកធ្វើការសិក្សា[២]។ ការជ្រើសជម្រើសនេះដោយសារតែមានគោលបំណងយកតែគំរូដែលជាតំណាងសំខាន់ៗ និងជាក្រុមក្នុងវិស័យនេះដែលយើងមានធនធាននិងចំណេះដឹងអាចធ្វើការជាមួយបាន។ ខាងក្រោមគឺជាលក្ខខណ្ឌជ្រើសរើសទាំង៣របស់យើង៖

- **ទម្រង់សិល្បៈ៖** ប្រមែប្រមូលព័ត៌មានទូលំទូលាយពីទម្រង់សិល្បៈទស្សនីយភាពចម្រុះគ្នា (តូរ្យតន្ត្រី របាំ សៀក និងល្ខោនជាដើម)។
- **ទីតាំងភូមិសាស្ត្រ៖** សិក្សាទាំងតំបន់ជនបទ និងទីក្រុង ដើម្បីធ្វើការប្រៀបធៀប ។
- **ក្របខណ្ឌ៖** បង្កនូវក្របខណ្ឌចម្រុះមួយចំនួន ដូចជា ក្របខណ្ឌសិល្បៈបែបអាជីវកម្ម បែបអង្គការសមាគមមិនមែនរដ្ឋាភិបាល និងបែបជាសិល្បករឯករាជ្យជាដើម ដែលនាំឲ្យយើងអាចវិភាគ និងវាយតម្លៃពីក្របខណ្ឌការងារផ្សេងៗនេះ ។

## ដំណាក់កាលនៃសន្ទង់

- បង្កើតនូវវិធីសាស្ត្រសន្ទង់និងកម្រងសំណួរ (ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ ខែមីនា ឆ្នាំ២០១៤)
- ចែកចាយនិងប្រមែប្រមូលកម្រងសំណួរ (ពីខែមីនា ឆ្នាំ២០១៤ ដល់ខែឧសភា ឆ្នាំ២០១៤)
- វិភាគនិងសរសេររបាយការណ៍នៃសន្ទង់នេះ (ពីខែមិថុនា ដល់ខែកក្កដា ឆ្នាំ២០១៤)

*១. ពីខែតុលា ឆ្នាំ២០១៣ ដល់ខែឧសភា ឆ្នាំ២០១៤*

*២. យើងក៏បានទទួលកម្រងសំណួរមួយចំនួនតូចត្រឡប់មកវិញពីខេត្តដ៏ទៃទៀតផងដែរ*

## ការបែងចែកក្រុមគំរូនិងកំណត់ចំណាំផ្សេងៗ

សិល្បករចំនួន៣៨០រូប និងធុរជនសិល្បៈចំនួន៨៤រូបបានបំពេញចម្លើយក្នុងកម្រងសំណួរដែលបានចែកចាយ។ តារាងខាងក្រោមនេះផ្តល់ទិន្នន័យពីទម្រង់សិល្បៈផ្សេងៗដែលត្រូវបានរួមបញ្ចូលក្នុងសន្ទង់នេះ ដោយមានអត្រាភាគរយផងដែរ។ចូរកត់ចំណាំថាមានសិល្បករមួយចំនួនពួកគេម្នាក់ៗប្រកបមុខរបរសិល្បៈច្រើនទម្រង់ (ឧទាហរណ៍ សិល្បករ៦៦ភាគរយ សម្តែងសិល្បៈចាប៉ីដងវែងផងនិងក្នុងវង់ភ្លេងពិណពាទ្យផង) ដូច្នេះយើងរាប់តួលេខពួកគេម្នាក់ៗទាំងនោះក្នុងទម្រង់ទាំងអស់ដែលនាំឲ្យចំនួនសរុបសិល្បករក្នុងតារាងលេខ១មានចំនួនលើស៣៨០។ចូរកត់ចំណាំដូចគ្នាដែរក្នុងតារាងលេខ ២ ធុរជនសិល្បៈមួយចំនួនមានតួនាទីលើសពីមួយ (ឧទាហរណ៍ ៥០ភាគរយជាការីពន្លឺផងជាការីសម្លេងផង)។

តូរ្យតន្ត្រីនិងរបាំមានចំនួនច្រើនជាងគេក្នុងក្រុមគំរូ។ ដោយឡែកចំពោះទម្រង់សិល្បៈសៀក ដោយសារ ពួកគេទូទៅមានឱកាសការងារច្រើន ហើយបើយោងតាមនិយមន័យក្រុមគំរូ «សិល្បករ[៣]» យើងអាចរួមបញ្ចូលចំនួន សិល្បករសៀកដែលមកពីអង្គការហ្វារពន្លឺសិល្បៈប៉ុណ្ណោះដែលបានបំពេញចម្លើយក្នុងកម្រងសំណួរ។អាស្រ័យហេតុនេះលទ្ធផលក្នុងសន្ទង់នេះដែលទាក់ទងនឹងទម្រង់សៀក គឺតំណាងឲ្យតែសិល្បករមកពីក្រុមសៀកហ្វារ[៤]តែប៉ុណ្ណោះ។

**តារាងលេខ១៖ សិល្បករដែលមានវត្តមានក្នុងសន្ទង់នេះរាយតាមទម្រង់សិល្បៈ**

| ផ្នែក | បរិមាណ | ទម្រង់សិល្បៈ | ចំនួន | ភាគរយគិតតាមផ្នែក |
|---|---|---|---|---|
| ល្ខោន | 140 | ល្ខោនបាសាក់ | 35 | 36,80% |
| | | ល្ខោននិយាយ | 21 | |
| | | ល្ខោនខោល | 8 | |
| | | ល្ខោនស្រមោលស្បែកធំ | 16 | |
| | | ល្ខោនស្រមោលស្បែកតូច | 10 | |
| | | ល្ខោនយីកេ | 50 | |
| តូរ្យតន្ត្រី | 218 | ចាប៉ីដងវែង | 3 | 57,40% |
| | | ភ្លេងការបូរាណ | 35 | |
| | | ភ្លេងសហសម័យ | 12 | |
| | | ភ្លេងកន្ត្រឹម | 2 | |
| | | ភ្លេងសម័យ | 44 | |
| | | ភ្លេងការសម័យ | 26 | |
| | | ភ្លេងមហោរី | 39 | |
| | | ស្មូត | 8 | |
| | | ភ្លេងពិណពាទ្យ | 49 | |
| សៀក | 36 | សៀក | 36 | 9,50% |
| របាំ | 220 | របាំបូរាណ | 73 | 57,90% |
| | | របាំសហសម័យ | 23 | |
| | | របាំទំនើប | 6 | |
| | | របាំប្រពៃណី | 118 | |

**តារាងលេខ២៖ ធុរជនសិល្បៈដែលមានវត្តមានក្នុងសន្ទង់នេះរាយតាមតួនាទីការងារ**

| ផ្នែក | បរិមាណ | តួនាទី ឬមុខងារ | ចំនួន | ភាគរយគិតតាមផ្នែក |
|---|---|---|---|---|
| អ្នកគ្រប់គ្រងរដ្ឋបាលនិងគម្រោងសិល្បៈ | 53 | បុគ្គលិករដ្ឋបាល និងគម្រោង | 7 | 64% |
| | | នាយក | 5 | |
| | | ប្រធានផ្នែក | 37 | |
| | | បុគ្គលិកទីផ្សា និងទំនាក់ទំនង | 4 | |
| អ្នកចាត់ការទូទៅសម្រាប់សិល្បករ | 27 | ប្រធានក្រុមសិល្បៈ | 27 | 32% |
| អ្នកបច្ចេកទេស | 19 | អ្នកគ្រប់គ្រងបច្ចេកទេសទូទៅ | 7 | 23% |
| | | អ្នកបច្ចេកទេសពន្លឺ | 4 | |
| | | អ្នកផាត់មុខ | 1 | |
| | | អ្នកបច្ចេកទេសសម្លេង | 7 | |

ចំណុចគួរកត់ចំណាំមួយទៀត គឺចំនួនខុសគ្នាតាមទម្រង់ ដែលទម្រង់ខ្លះមានចំនួនសរុបច្រើនជាងទម្រង់ខ្លះទៀត។ ដូច្នេះ លទ្ធផលដែលសរុបបានត្រូវវិភាគដោយមានការពិចារណាអំពីចំនួនខុសគ្នាទាំងនេះដើម្បីជៀសវាងការធ្វើសេចក្តីសន្និដ្ឋានណាមួយដោយមិនបានគិតគ្រប់ជ្រុងជ្រោយ។ការសិក្សាបន្ថែមដើម្បីពិចារណាអំពីទិដ្ឋភាពសំខាន់ៗដែលពាក់ព័ន្ធនឹងអាចផ្តល់នូវភាពស៊ីជម្រៅលើសពីព័ត៌មានដែលបានមកតែពីក្រុមគំរូនិងអាចផ្តល់នូវគំនិតផ្តួចផ្តើមផ្សេងៗជួយពង្រឹងដល់វិស័យសិល្បៈនេះ។ របកគំហើញទាំងឡាយក្នុងសន្ទង់នេះ ជាតំណាងមួយ និងមិនបង្ហាញនូវទិដ្ឋភាពទាំងស្រុងក្នុងវិស័យនេះបាននោះទេ។

ម្យ៉ាងវិញទៀតយើងបានជួបប្រទះនឹងការលំបាកមួយទៀតត្រង់ថាសិល្បករដែលចូលរួមក្នុងសន្ទង់នេះ មានកម្រិតវប្បធម៌ដែលមានគម្លាតខុសគ្នាខ្លាំង ជាពិសេសគម្លាតរវាងសិល្បករនៅទីក្រុងនិងនៅជនបទ។ យើងបានប្រឹងប្រែងគ្រប់បែបយ៉ាងក្នុងការនិពន្ធនូវកម្រងសំណួរឡើងប្រកបដោយភាពច្បាស់លាស់ តែទោះជាយ៉ាងនេះក្តី ពួកគាត់មួយចំនួនមិនអាចយល់សំណួរមួយចំនួនបានដោយសារតែមានភាពស្មុគស្មាញខ្លះ។ ក្នុងចំណោមសិល្បករចូលរួមមានសិល្បករខ្លះជាអនក្ខរជន ដែលពួកគាត់ត្រូវការជំនួយក្នុងការបំពេញចម្លើយក្នុងកម្រងសំណួរ។ ទោះជាមានការពន្យល់អំពីសារៈសំខាន់ទិសដៅ និងផលប្រយោជន៍នៃសន្ទង់ចំពោះពួកគាត់ក៏ដោយសិល្បករមួយចំនួនមិនចង់ចូលរួម ឬអ្នកខ្លះទៀតមិនទុកចិត្តក្នុងការផ្តល់ព័ត៌មានផ្ទាល់ខ្លួន (បើទោះជាសន្ទង់នេះមានលក្ខណៈជាអនាមិកក៏ដោយ)។

ការស្វែងរកចម្លើយនៃសន្ទង់នេះ ភាគច្រើនយើងបានធ្វើឡើងនៅពេលសិល្បករត្រូវទៅសម្តែង និងក្រោយពេលសម្តែង។ ប៉ុន្តែ ជាញឹកញយសិល្បករមានការនឿយហត់ពេកពីការធ្វើដំណើរផ្លូវឆ្ងាយ ហើយពួកគេក៏ត្រូវរវល់រៀបចំឆាកទៀតមុនពេលសម្តែង។ ជាលទ្ធផល ជួនកាលយើងមិនបានទទួលកម្រងសំណួរនេះត្រឡប់មកវិញតាមចំនួនគោលដៅដែលយើងបានគ្រោងនោះឡើយ ហើយមានសំណួរខ្លះទៀតត្រូវបានគេរំលងមិនបានផ្តល់ចម្លើយ។

ចំពោះក្រុមគំរូធុរជនសិល្បៈ លទ្ធផលដែលទទួលបានក៏មានកំណត់ ដោយសារតែបរិមាណនៃក្រុមសំណាកនេះមានគ្នាតែ៨៤រូប ដែលធ្វើឲ្យការបែងចែកជាក្រុមមុខងារឬតួនាទីមានការលំបាក។ គួរកត់សម្គាល់ផងដែរថា ធុរជនប្រមាណ៥៨ភាគរយគឺជាសិល្បករដែរ ដែលចំណូល៣០ភាគរយរបស់ពួកគាត់បានមកពីការសម្តែង។

## កំណត់ចំណាំបន្ថែម

- ទិន្នន័យទាំងឡាយក្នុងសន្ទង់នេះចែងជា «ភាគរយ» នៃអ្នកចូលរួមផ្តល់ចម្លើយ។
- ជាទូទៅតួលេខភាគរយទាំងឡាយ ត្រូវបានតម្លើងឬបន្ថយទៅរកចំនួនគត់ដែលប្រហាក់ប្រហែលបំផុត។
- កម្រងសំណួរត្រូវបាននិពន្ធឡើងដោយចែកប្រភេទសំណួរជា២៖
  - ប្រភេទទី១ ជាសំណួរចោទទៅលើប្រតិបត្តិក្នុងជីវភាពសិល្បៈ (ឧទាហរណ៍ តើអ្នកបានសម្តែងប៉ុន្មានដងក្នុងឆ្នាំ២០១៣?)
  - ប្រភេទទី២ ជាសំណួរចោទលើទស្សនៈពេលអនាគត (ឧទាហរណ៍ តើអ្នកមានបំណងនឹងធ្វើអ្វីនាពេលអនាគត?)

យើងសូមសង្កត់ធ្ងន់លើលក្ខណៈខុសគ្នានៃប្រភេទសំណួរទាំង២នេះ។ ប្រភេទទី១ផ្តោតទៅលើព័ត៌មានជាក់ស្តែង រីឯប្រភេទទី២ទាញយកនូវអារម្មណ៍របស់សិល្បករ។ ចម្លើយដែលទទួលបានពីសំណួរទាំង២ប្រភេទនេះមានការពាក់ព័ន្ធនឹងគ្នាតែចម្លើយទាំងនេះមិនត្រូវលាយឡំបញ្ចូលគ្នាឡើយ។

សន្ទង់នេះបែងចែកជា៣ភាគ។ ភាគទី១ យើងសិក្សាទៅលើទិដ្ឋភាពសង្គមទូទៅនៃក្រុមគំរូ។ ភាគទី២ យើងពិនិត្យមើលលើស្ថានភាពការងារប្រចាំថ្ងៃរបស់សិល្បករនិងធុរជន និងចុងក្រោយបំផុត យើងធ្វើសេចក្តីសន្និដ្ឋានដោយប្រើសម្មតិកម្មនៃស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ។

*៣. សូមមើលនិយមន័យក្រុមគំរូឬក្រុមសំណាក ទំព័រ៧*

*៤. នេះជាអង្គភាព២ដែលមានសម្ព័ន្ធនិងគ្នា គឺអង្គការហ្វារពន្លឺសិល្បៈដែលជាអង្គការក្រៅរដ្ឋាភិបាល និងនិងសហគ្រាសហ្វារពន្លឺសិល្បៈដែលជាអាជីវកម្មសង្គម។ សម្រែសម្រួលមក អង្គការហ្វារពន្លឺសិល្បៈផ្តល់ការបណ្តុះបណ្តាលជំនាញសិល្បៈ ចំណែកឯសហគ្រាសហ្វារពន្លឺសិល្បៈផ្តល់មុខរបរនិងការងារសិល្បៈ។ អង្គភាពទាំង២នេះ មានការចល័តនិងផ្លាស់ប្តូរសិល្បករគ្នាទៅវិញទៅមក។*



# I ទិដ្ឋភាពសង្គមទូទៅនៃវិស័យសិល្បៈខ្មែរ

ភាគទី១នៃសន្ទង់នេះ សិក្សាទៅលើទិដ្ឋភាពសង្គមនៃក្រុមសំណាកទាំង២ គឺសិល្បករនិងធុរជនសិល្បៈ ដោយផ្អែកទៅលើសណ្ឋានប្រជាជន (អាយុ ភេទ កម្រិតវប្បធម៌ មុខរបរឪពុកម្តាយ ។ល។)។

## ១. ភេទ

ធៀបនឹងចំនួនប្រជាជនទាំងមូល យើងឃើញថា បរិមាណសិល្បករ និងធុរជនបុរសមានចំនួនលើសលប់លើបរិមាណសិល្បការិនីនិងធុរជនស្ត្រី។ ក្រុមគំរូសិល្បករ មានចំនួនប្រមាណ៣៩ភាគរយជាស្ត្រី និង៦១ភាគរយជាបុរស ចំណែកឯក្រុមគំរូធុរជន មានប្រមាណ៣៨ភាគរយជាស្ត្រី និង៦២ភាគរយជាបុរស (សូមមើលតារាងតួលេខទី១)។ ដើម្បីជួយដល់ការប្រៀបធៀប សូមបញ្ជាក់ថាចំនួនប្រជាជន កម្ពុជាទាំងមូលមានតួលេខបុរស ៤៨,៦ភាគរយ និងស្ត្រី៥១,៤ភាគរយ[៥]។

## ២. ក្រុមសំណាក២ក្រុមមានគោលបំណងតែ១ គឺការធ្វើឲ្យរស់ឡើងវិញនូវសិល្បៈខ្មែរ

បើពិនិត្យទៅលើអាយុរបស់សិល្បករតារាងតួលេខទី២បង្ហាញថាលំដាប់អាយុនៃសិល្បករ ដែលភាគច្រើនមានអាយុតិច។ ក្នុងលំដាប់អាយុច្រើនអត្រាសិល្បករមានចំនួនតិចហើយលំដាប់អាយុតិចអត្រាសិល្បករមានចំនួនច្រើន។ តួលេខផ្តល់នូវអត្រាចំនួន៧៣ភាគរយនៃសិល្បករមានអាយុតិចជាង៣០ឆ្នាំ និងអាយុមធ្យមរបស់សិល្បករគឺ ២៦ឆ្នាំ។ របបខ្មែរក្រហមបានធ្វើឲ្យសិល្បករខ្មែរបាត់បង់ជីវិតស្ទើរតែអស់ហើយសិល្បករវ័យក្មេងដែលសមាសភាពដ៏ធំមួយក្នុងក្រុមសំណាក ជាអ្នកបន្តវេនដើម្បីអភិរក្ស អភិវឌ្ឍ និងផ្សព្វផ្សាយសិល្បៈខ្មែរ។ តួលេខទទួលបាននេះ ហាក់ដូចជាសមស្របនឹងតួលេខជំរឿនប្រជាជនថ្នាក់ជាតិដែលមានចែងថាប្រជាជនកម្ពុជាប្រហែល៥០ភាគរយមានអាយុតិចជាង២៥ឆ្នាំ[៦]។បើក្រលេកមើលតួលេខនេះនៃធុរជនសិល្បៈវិញ យើងឃើញថាជាក្រុមដែលមានលំដាប់អាយុច្រើនជាងសិល្បករ។ ធុរជនមានតែ១៦ភាគរយប៉ុណ្ណោះដែលមានអាយុតិចជាង២៥ឆ្នាំ និងអាយុជាមធ្យមរបស់ធុរជនគឺ៣៥ឆ្នាំ (សូមមើលតារាងតួលេខទី៣)។

**៧៣% នៃក្រុមសំណាកសិល្បករមានអាយុតិចជាង ៣០ឆ្នាំ**

តួលេខទី២៖ លំដាប់អាយុនៃក្រុមសំណាកសិល្បករ




តួលេខទី៣៖ លំដាប់អាយុនៃក្រុមសំណាកធុរជនសិល្បៈ




តួលេខទី១៖ បរិមាណនៃក្រុមគំរូ




តួលេខទី៤៖ ស្ថានភាពអាពាហ៍ពិពាហ៍




៥. *វិទ្យាស្ថានស្ថិតិជាតិ - ជំរឿនប្រជាជនឆ្នាំ២០០៨ រួមសហការជាមួយ Redatam + SP ECLAC/CELADE 2010-2013*
៦. *សៀវភៅព័ត៌មានពិភពលោករបស់ CIA សម្រង់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣*

## តួលេខទី៥៖ កម្រិតវប្បធម៌




ស្របជាមួយគ្នានេះ លទ្ធផលនៃស្ថានភាពគ្រួសារបានបង្ហាញថា៣២ភាគរយនៃសិល្បកររៀបការរួច និង៣៥ភាគរយមានកូន ( សូមមើលតួលេខទី ៤ )។ អត្រាកូនមានកម្រិតកូនចំនួន២ក្នុង១គ្រួសារ[៧] ដែលជាអត្រាទាបបន្តិចបើធៀបនឹងអត្រាកូនថ្នាក់ជាតិដែលមានចំនួន២,៣។ ខុសពីក្រុមសំណាកសិល្បករ ក្រុមសំណាកធុរជនសិល្បៈមានអត្រាខ្ពស់ជាង គឺអ្នករៀបការរួច ៦២ភាគរយ អ្នកមានកូន៦១ភាគរយ និងអត្រាកូន២,៥ក្នុងមួយគ្រួសារ។

ចំពោះកម្រិតវប្បធម៌ តារាងតួលេខទី៥ផ្ដល់ព័ត៌មានថា ៥០ភាគរយនៃសិល្បករមានសញ្ញាបត្របាក់ឌុបនិង១៥ភាគរយមានសញ្ញាបត្របរិញ្ញាបត្រ ( ១១ភាគរយសញ្ញាបត្រក្នុងមុខវិជ្ជាសិល្បៈនិង៤ភាគរយក្នុងមុខវិជ្ជាក្រៅពីសិល្បៈ )។ ទន្ទឹមនឹងនេះសិល្បករ ២៤ភាគរយដែលបានបញ្ចប់ថ្នាក់មធ្យមសិក្សា ឥឡូវកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រក្នុងផ្នែកផ្សេងៗ ដែល១២ភាគរយកំពុងបន្តបរិញ្ញាបត្រផ្នែកសិល្បៈ។ ធុរជនសិល្បៈ មានអត្រាទទួលការសិក្សាខ្ពស់ជាងដែលមូលហេតុងាយយល់មួយគឺលំដាប់អាយុខ្ពស់ជាង។ មូលហេតុមួយទៀតគឺ ជំនាញក្នុងការងាររបស់ធុរជន សម្បូរទៅដោយការអប់រំបណ្ដុះបណ្ដាលក្នុងវិស័យដ៏ទៃក្រៅពីរង្វង់សិល្បៈ។ ដោយសារកត្តានេះ ធុរជនសិល្បៈ៥០ភាគរយបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងមានតែ ២២ភាគរយប៉ុណ្ណោះដែលមានគ្មានសញ្ញាបត្របាក់ឌុប។

យើងអាចសន្និដ្ឋានថា ក្រុមសំណាកទាំង២ មានបញ្ហាប្រឈមផ្សេងៗគ្នា។ ដូចដែលបានបរិយាយខាងលើវិស័យសិល្បៈនាពេលបច្ចុប្បន្ននេះ ត្រូវការឲ្យសិល្បករជំនាន់ថ្មី បានទទួលការបណ្ដុះបណ្ដាល ដើម្បីក្លាយជាសិល្បករអាជីព និងផ្សព្វផ្សាយសិល្បៈបន្តឲ្យបានកាន់តែទូលំទូលាយ។ ប៉ុន្តែគោលដៅមិនអាចសម្រេចបានទេ បើផ្ដោតតែលើការបណ្ដុះបណ្ដាលបច្ចេកទេសសិល្បៈសុទ្ធសាធនោះ។ ជំនាញដ៏ទៃជាច្រើន ដែលអាចទទួលបានពីវិស័យខាងក្រៅ ដូចជា សេដ្ឋកិច្ច ទីផ្សារ ទំនាក់ទំនង ធុរកិច្ចទូទៅ ការគ្រប់គ្រងបច្ចេកទេសជាដើម ត្រូវតែយកមកដាក់បញ្ចូលតាមរយៈកម្លាំងការងាររបស់ធុរជន ដើម្បីចូលរួមជាមួយសិល្បករក្នុងការជំរុញឲ្យវិស័យសិល្បៈមានភាពខ្លាំងក្លានិងមានសន្ទុះរីកចម្រើន។

## ៣. ក្រុមសំណាកមានទីលំនៅក្នុងទីក្រុងមានចំនួនច្រើនជាងដែលជាកត្តាកំណត់លើវិស័យទាំងមូល

តួលេខទី៦ បង្ហាញតួលេខបញ្ចូលគ្នាទាំងសិល្បករនិងធុរជនសិល្បៈ[៨]។ ដូចដែលបានឃើញក្នុងតួលេខនេះសិល្បករនិងធុរជនសិល្បៈភាគច្រើនមានដើមកំណើតពីគ្រួសារដែលមានជីវភាពមិនសូវធូរធារនោះទេ។ ៣៦ភាគរយនៃឪពុកនិង៣២ភាគរយនៃម្ដាយរបស់ពួកគេ គឺជាពលករ កសិករ និងជាកម្មកររោងចក្រ។ ក្រៅពីនេះឪពុកចំនួន២៤ភាគរយស្លាប់ និងម្ដាយចំនួន ១៩ភាគរយជាមេផ្ទះ។

ទីលំនៅបច្ចុប្បន្នរបស់ក្រុមសំណាក មានភាពខុសប្លែកគ្នាក្នុងដើមកំណើតគ្រួសាររបស់ពួកគេ ( សូមមើលផែនទីលេខ១ )។ ទោះជាក្រុមសំណាកភាគច្រើនមកពីគ្រួសារពលករនិងជាពិសេសកម្មករក៏ដោយ យើងសង្កេតឃើញ៦០ភាគរយនៅក្រុមសំណាករស់នៅក្នុងទីក្រុងសំខាន់ៗក្នុងប្រទេសកម្ពុជា ដូចជាទីក្រុងភ្នំពេញ សៀមរាប និងបាត់ដំបងជាដើម។

វិស័យអប់រំ ទេសចរណ៍ តម្រូវការពលកម្ម និងចំនួនច្រើននៃអង្គការសមាគមសិល្បៈនៅក្នុងទីក្រុង ញ៉ាំងឲ្យសិល្បករជំនាន់ថ្មីធ្វើចំណាកស្រុកផ្លាស់ទីមករស់នៅក្នុងទីក្រុង។ ដូច្នេះ ការផ្លាស់ទីនេះ ជាបាតុភូតមួយកំពុងកើតឡើងក្នុងប្រទេស ហើយជះឥទ្ធិពលលើវិស័យសិល្បៈទាំងមូល។

## តួលេខទី៦៖ មុខរបរឪពុកម្ដាយរបស់ក្រុមសំណាកក្នុងវិស័យសិល្បៈទស្សនីយភាព បង្ហាញពីដើមកំណើតភាគច្រើនមកពីជនបទ




*៧. អត្រាកូនគឺជាចំនួនមធ្យមកូនដែលស្ត្រីក្នុងតំបន់ភូមិសាស្ត្រមួយអាចបង្កើតបានគិតក្នុងមួយអាយុជីវិត*
*៨. យើងដាក់តួលេខបញ្ចូលគ្នាដោយសារលទ្ធផលនៃក្រុមសំណាកទាំង២មានលក្ខណៈស្រដៀងខ្លាំង*

## ផែនទីលេខ១៖ ខេត្តដែលបានចុះសិក្សា








# II
# ស្ថានភាពសិក្សានិងការងារ៖ ក្រុមសំណាកសិល្បករកំពុងស្ថិតក្នុងដំណាក់កាលឈានទៅរកភាពអាជីព

ភាគទី២នៃសន្ទង់នេះ ផ្តោតទៅលើស្ថានភាពសិក្សានិងការងារសិល្បករនិងធុរជនសិល្បៈខ្មែរ ដោយផ្អែកទៅលើកត្តាមួយចំនួនរួមមាន ម៉ោងពេលការងារ ប្រាក់កំរៃ សកម្មភាពការងារ និងកម្រិតសមត្ថភាពការងារ (ការហាត់រៀនសូត្រខ្លួនឯង ការហាត់សម ការបង្ហាត់ និងការសម្តែង)។

## ១. ក្របខណ្ឌការងារ (ការសម្តែងជាការងារចម្បង)

### តួលេខទី៧៖ មុខរបរនិងការងាររបស់សិល្បករ




### តួលេខទី៨៖ ក្របខណ្ឌការងារ




### តួលេខទី៩៖ ប្រភេទស្ថាប័នឬអង្គភាព




### តួលេខទី១០៖ មុខរបរនិងការងាររបស់ធុរជនសិល្បៈ




សិល្បករចំនួន៨២ភាគរយជាអ្នកសម្តែង និង២៦ភាគរយជាគ្រូបង្ហាត់ដែលជាមុខរបរសិល្បៈអាជីពសម្រាប់សិល្បករ (សូមមើលតារាងតួលេខទី៧)។ ក្នុងចំណោមនោះសិល្បករប្រមាណ៥៧ភាគរយមានការងារទៀងទាត់ជាមួយស្ថាប័នឬអង្គភាពមួយ ហើយ៤២ភាគរយនៃពួកគេមានកិច្ចសន្យាការងារ។ (សូមមើលតារាងតួលេខទី៨)។

បើពិនិត្យប្រភេទស្ថាប័នឬអង្គភាពដែលពួកគេធ្វើការយើងសង្កេតឃើញថា អង្គការសមាគមក្រៅរដ្ឋាភិបាលជាប្រភេទស្ថាប័នដែលសិល្បករមានការងារជាមួយច្រើនជាងគេ គឺមានរហូតដល់២៧ភាគរយ (សូមមើលតារាងតួលេខទី៩)។ នេះមិនមែនបានសេចក្តីថា សិល្បករមិនធ្វើការក្នុងក្រុមហ៊ុនឯកជននោះទេប៉ុន្តែទំនាក់ទំនងមុខរបរនិងការងាររបស់សិល្បករនិងអង្គការសមាគមក្រៅរដ្ឋាភិបាលមានភាពឈានមុខជាងស្ថាប័នឬអង្គភាពប្រភេទផ្សេងទៀត។ ចូរចងចាំថានេះអាចដោយសារតែសន្ទង់នេះសិក្សាទៅលើសំណាកដែលរកបានតាមបណ្តាញការងារក្នុងចំណោមអង្គការសមាគម។

### តួលេខទី១១៖ ម៉ោងការងាររបស់ធុរជនសិល្បៈ



ដោយវិសាលភាពនៃការងារសម្តែងក្នុងវិស័យសិល្បៈ ការងារចម្បងសម្រាប់ធុរជនសិល្បៈ គឺការរៀបចំសម្រាប់ការសម្តែងរបស់សិល្បករ។ ដូច្នេះ តារាងតួលេខទី១០បង្ហាញអំពីមុខងាររបស់ធុរជនសិល្បៈ ដែលមាន២៣ភាគរយនៃពួកគេ ជាអ្នកបច្ចេកទេស រួមទាំងការីពន្លឺ សម្លេង ជំនួយការទូទៅ និងអ្នកផាត់មុខ។ តួលេខបន្ទាប់គឺ ធុរជន៣២ភាគរយជាអ្នកចាត់ការទូទៅសម្រាប់សិល្បករនិងក្រុមសិល្បៈ និងតួលេខខ្ពស់ជាងគេគឺ ៦៤ភាគរយមានមុខងារការងារក្នុងផ្នែកហិរញ្ញវត្ថុ ទំនាក់ទំនង និងគ្រប់គ្រងកម្មវិធី។ ដូចសិល្បករដែរ ធុរជនសិល្បៈភាគច្រើនមានមុខរបរនិងការងារជាមួយអង្គការសមាគមមិនមែនរដ្ឋាភិបាល[៩]។

ទិន្នន័យការងារប្រចាំថ្ងៃរបស់ពួកគេ(សូមមើលតារាង តួលេខទី១១) បង្ហាញថាធុរជនសិល្បៈភាគច្រើនបំផុត(៦៩ភាគរយ)ធ្វើការងារពេញម៉ោងក្នុងវិស័យសិល្បៈ១៣ភាគរយធ្វើការងារពាក់កណ្តាលពេញម៉ោងនិង៨ភាគរយធ្វើការ១ភាគ៤ពេញម៉ោង។ រីឯ១០ភាគរយផ្សេងទៀត ពួកគេគ្មានម៉ោងការងារពិតប្រាកដ ដែលពួកគេនោះជាអ្នកបច្ចេកទេស និងអ្នកចាត់ការទូទៅសម្រាប់សិល្បករដែលមានម៉ោងការងារបត់បែនតាមការសម្តែង។

## ២. ការងារបង្ហាត់

ការងារបង្ហាត់សិល្បៈមានអត្រាចំនួន២៦ភាគរយនៃក្រុមគំរូ។ភាគច្រើនគឺជាបុរស (ដែលមានរហូតទៅដល់៦៣ភាគរយ) និងមានអាយុច្រើនជាងលំដាប់អាយុជាមធ្យមក្នុងក្រុមគំរូ (អាយុ៣២ឆ្នាំធៀបនឹងអាយុជាមធ្យមនៃសិល្បករតែ២៦ឆ្នាំប៉ុណ្ណោះ)។ ម៉ោងបង្ហាត់ជាមធ្យមគឺ ៩,៥ម៉ោងក្នុង១សប្តាហ៍ (មិនរាប់ទាំងម៉ោងរៀបចំត្រៀមបង្រៀននោះទេ) ហើយប្រាក់កំរៃជាមធ្យមគឺ៧,៦ដុល្លារអាមេរិចក្នុង១ម៉ោង ដែលនាំឲ្យប្រាក់កំរៃមធ្យមប្រចាំខែមានចំនួន២៨៨ដុល្លារអាមេរិច។ ប៉ុន្តែ ដោយសារលទ្ធផលដែលទទួលបាន

### ជំនាញចាំបាច់៖ ជំនាញប្រើប្រាស់កុំព្យូទ័រ

បច្ចុប្បន្ននេះ ការងារភាគច្រើនតម្រូវឲ្យមានចំណេះដឹងផ្នែកកុំព្យូទ័រ។ តាមរយៈអ៊ិនធើណិត សិល្បករអាចរកព័ត៌មានផ្សេងៗបានបរិមាណយ៉ាងច្រើនសន្ធឹកសន្ធាប់ទាក់ទងនិងសិល្បៈរបស់ខ្លួនដែលមានទាំងវីដេអូ បទភ្លេង និងគេហទំព័រជាច្រើនទៀត។ ការប្រើប្រាស់នេះ ក៏ផ្តល់លទ្ធភាពដល់សិល្បករទំនាក់ទំនងជាមួយអ្នកដ៏ទៃ រកមើលព័ត៌មានអំពីការសម្តែងផ្សេងៗ បង្កើតទំនាក់ទំនងការងារ និងពង្រីកបណ្តាញទំនាក់ទំនងក្នុងអាជីពការងារ។ យើងសូមផ្តល់នូវកំណត់សម្គាល់ថា ត្រង់សំណួរក្នុងចំនុចនេះ យើងទទួលបានអត្រាចម្លើយទាប ដូច្នេះ យើងពិបាកនឹងធ្វើសេចក្តីសន្និដ្ឋានដែលមានសុក្រិតភាព១០០ភាគរយទេ តែយើងលទ្ធផលជាក់ស្តែងដែលទទួលបានបង្ហាញនូវភាពវិជ្ជមានខ្ពស់។

៤៣ភាគរយនៃសិល្បករដែលចូលរួមក្នុងសន្ទង់នេះ ប្រើប្រាស់អ៊ិនធើណិតយ៉ាងហោចម្តងក្នុងមួយថ្ងៃ ហើយ២១ភាគរយទៀតប្រើអ៊ិនធើណិតម្តងក្នុងមួយសប្តាហ៍ (សូមមើលតារាងតួលេខទី១២)។ អ្នកដែលមិនប្រើអ៊ិនធើណិតសោះមានអត្រាតែ២៦ភាគរយប៉ុណ្ណោះ។ បើតាមទិន្នន័យឆ្នាំ២០១២ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ប្រជាជនខ្មែរដែលប្រើប្រាស់អ៊ិនធើណិតមានតែ១៦ភាគរយប៉ុណ្ណោះនៃចំនួនប្រជាជនទាំងមូល[១០]។ លទ្ធផលតួលេខបែបនេះ គឺដោយសារបរិមាណខ្ពស់នៃយុវជននិងភូមិសាស្ត្រទីលំនៅរបស់ពួកគេ ប៉ុន្តែទោះជាតួលេខនេះទាបក្តី តាមរយៈលទ្ធផលនេះ យើងអាចបកស្រាយបានថា ពួកគេមានចំណេះដឹងថ្នាក់មូលដ្ឋានក្នុងការប្រើប្រាស់អ៊ិនធើណិតនេះនិងអាចបន្តរៀនជំនាញបន្ថែម ដែលជាគុណប្រយោជន៍របស់វិស័យព័ត៌មានវិទ្យា។ លទ្ធផលដ៏ទៃទៀតក្នុងជំនាញនេះ គឺសិល្បករ៥២ភាគរយមានប្រើសារអេឡិចត្រូនិច ៧៩ភាគរយមានប្រើ Facebook ៧៣ភាគរយមានប្រើ Youtube និង៤៨ភាគរយមានប្រើកម្មវិធី Word[១១]។ ចំណែកឯធុរជនសិល្បៈ មានចំណេះដឹងក្នុងជំនាញកុំព្យូទ័រល្អប្រសើរជាង។ តួលេខបង្ហាញថា ធុរជន៧០ភាគរយមានប្រើសារអេឡិចត្រូនិច ៦៥ភាគរយមានប្រើ Youtube ៥៥ភាគរយមានប្រើFacebook ៤៤ភាគរយមានប្រើកម្មវិធី Word ។

អ្វីដែលគួរឲ្យចាប់អារម្មណ៍ គឺការប្រើប្រាស់ទាំងអស់នេះជាមធ្យោបាយដែលពួកអភិវឌ្ឍជំនាញអាជីពរបស់ខ្លួន ហើយសិល្បករភាគច្រើនបានផ្តល់ចម្លើយថាការបណ្តុះបណ្តាលកុំព្យូទ័រជាតម្រូវការចាំបាច់មួយ។

តួលេខទី១២៖ ជំនាញផ្នែកកុំព្យូទ័រ




៩. ចូរកត់ចំណាំថាការជ្រើសរើសក្រុមគំរូមានឥទ្ធិពលលើលទ្ធផលទទួលបាន ។ សូមមើល «វិធីសាស្ត្រសិក្សា» ។
១០. របាយការណ៍ស្ថានភាពទូរគមនាគមន៍នៅកម្ពុជា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឆ្នាំ២០១២
១១. អត្រានៃការមិនផ្តល់ចម្លើយ៖ Word (54%), Facebook (35%), Email (60%), Youtube (44%)

មានផ្ទុកនូវគម្លាតធំពេកក្នុងតម្លៃប្រាក់កំរៃការងារ យើងមិនអាចគណនាប្រាក់ខែមធ្យមបានត្រឹមត្រូវទេ តែយើងអាចផ្តល់តួលេខប្រាក់កំរៃបានពីការបង្ហាត់សិល្បៈក្នុងមួយខែ គឺមានតម្លៃពី៥ដុល្លាររហូតដល់៦៥០ដុល្លារ។ ប្រាក់កម្រៃថ្នាក់កណ្តាល (មិនមែនប្រាក់កំរៃមធ្យមទេ)[១២] គឺ៨០ដុល្លារអាមេរិចក្នុងមួយខែ។តួលេខនេះអាចផ្តល់នូវព័ត៌មានប្រាក់ចំណូលជាក់ស្តែងរបស់សិល្បករក្នុងរបរបង្ហាត់ ហើយ៧៧ភាគរយនៃសិល្បករជាគ្រូបង្ហាត់ទាំងនេះ គឺជាអ្នកសម្តែងដែរ។

## ៣. ការហាត់និងការត្រៀមខ្លួនមុនពេលសម្តែង

ពេលវេលាហាត់សមរបស់សិល្បករ ជាផ្នែកសំខាន់មួយក្នុងជីវិតអាជីព។ ការហាត់សមធ្វើឲ្យពួកគេទទួលនិងដុសខាត់ជំនាញសិល្បៈដើម្បីអាចសម្តែងចំពោះមុខទស្សនិកជនក្នុងកម្រិតគុណភាពសិល្បៈមួយដែលសក្តិសមទៅនឹងប្រាក់កំរៃការងារ។ លទ្ធផលដែលទទួលបានពីសន្ទង់នេះបង្ហាញថា សិល្បករ ៦៦ភាគរយនៅកំពុងសិក្សាសិល្បៈនៅឡើយ។ ដូចករណីមួយចំនួនពីខាងដើមដែរ លទ្ធផលនេះ គឺដោយសារតែចំនួនយុវជនក្នុងសន្ទង់នេះ មានចំនួនច្រើន ដែលស្ថិតក្នុងវ័យសិក្សានិងលទ្ធផលនេះក៏ជាសក្ខីកម្មមួយថាវិស័យសិល្បៈខ្មែរកំពុងស្ថិតក្នុងដំណាក់កាលពិសេសដោយឡែកមួយ។ ការកសាងឡើងវិញនូវវិស័យសិល្បៈវប្បធម៌បន្ទាប់ពីសោកនាដកម្មកាលពីសម័យខ្មែរក្រហមត្រូវការពេលវេលាយូរនិងកិច្ចប្រឹងប្រែងធំធេង។យើងឈានដល់ជំនាន់សិល្បករបន្ទាប់មួយទៀតនៃការបន្តវេនសិល្បៈបន្ទាប់ពីរបបខ្មែរក្រហម ហេតុនេះហើយសំណាកភាគច្រើននៃសន្ទង់នេះ នៅកំពុងនៅសិក្សានៅឡើយ ។ជាមួយគ្នានេះដែរ ៣៩ភាគរយនៃពួកគេទៅរៀនសិល្បៈរាល់ថ្ងៃ(សូមមើលតារាងតួលេខ១៣) និង៣៦ភាគរយទៀតទៅរៀនពី២ទៅ៥ដងក្នុង១សប្តាហ៍។ មានសិល្បករ៣៦ភាគរយដែលហាត់រៀនសិល្បៈដោយខ្លួនឯងរាល់ថ្ងៃ និង៣៤ភាគរយហាត់រៀន២ទៅ៣ដងក្នុងមួយសប្តាហ៍។ ចំពោះការហាត់ជាក្រុមវិញ ៦៦ភាគរយហាត់សមជាក្រុមយ៉ាងតិចម្តងក្នុងមួយសប្តាហ៍។ យោងតាមសម្មតិកម្មទាំងនេះ យើងអាចទាញសេចក្តីសន្និដ្ឋានបានថាវិស័យសិល្បៈខ្មែរ

- សិល្បករ ៦៦% កំពុងរៀនសិល្បៈ
- សិល្បករ ៦៧% ហាត់សមយ៉ាងតិចម្តងក្នុងមួយសប្តាហ៍
- សិល្បករ ៧០% ហាត់រៀនខ្លួនឯងយ៉ាងតិច២ដងក្នុងមួយសប្តាហ៍

### តួលេខទី១៣៖ ពេលវេលាបណ្តុះបណ្តាលសិល្បៈក្នុងឆ្នាំ២០១៣




### តម្រូវការសម្ភារៈ

សិល្បករមួយចំនួនផ្តល់ចម្លើយថាពួកគេត្រូវការឧបករណ៍ដើម្បីលើកកម្ពស់ស្ថានភាព ការងារអាជីពរបស់ខ្លួន ជាពិសេសគឺឧបករណ៍ភ្លេង ។

### ទីកន្លែងហាត់សម

សិល្បករមួយចំនួនផ្តល់ចម្លើយថាពួកគេគ្មានទីតាំងគ្រប់គ្រាន់សម្រាប់ការហាត់រៀនខ្លួន និងការហាត់សមផ្សេងៗ ។

### សុខភាព

សិល្បករខ្លួនផ្តល់ចម្លើយថាមានបញ្ហាសុខភាពរាងកាយដោយសារសកម្មភាពសិល្បៈ។ ការសិក្សាអំពីចំណុចនេះអាចធ្វើទៅបានដើម្បីកំណត់ថាអ្វីដែលជាផលវិបាកលើរាងកាយដោយសារសកម្មភាពសិល្បៈ និងអ្វីដែលអាចធ្វើទៅបានដើម្បីបញ្ចៀសផលវិបាកនេះ។



១២. ប្រាក់កំរៃអេង្គកណ្តាលគឺជាតម្លៃតួលេខទឹកប្រាក់នៅកណ្តាលគេជាក់ស្តែង (ឬអង្គកណ្តាលគេ) គឺថាបើយើងរាយគ្រប់អង្គទាំងអស់នៃតម្លៃប្រាក់ខែពីទាបបំផុតដល់ខ្ពស់បំផុត អង្គដែលនៅកណ្តាលគេជាក់ស្តែងនោះ គឺជាប្រាក់កំរៃអេង្គកណ្តាលនៃតម្លៃប្រាក់ខែទាំងអស់។ ដោយឡែកប្រាក់ខែមធ្យមនៃក្រុម១ គឺជាការគណនាដោយយកតម្លៃនីមួយៗក្នុងក្រុមនោះ បូកសរុបបញ្ចូលគ្នា ហើយចែកនឹងចំនួនអង្គនៃក្រុមនោះដើម្បីរកមធ្យមភាគ ។

## ជំនាញចាំបាច់៖ ជំនាញបច្ចេកទេសសិល្បៈ

សិល្បករមួយចំនួនបានផ្តល់ចម្លើយ អំពីចំណាប់អារម្មណ៍ក្នុងការជុសខាត់ជំនាញសិល្បៈរបស់ខ្លួន និងរៀនសូត្រទម្រង់សិល្បៈបន្ថែមទាំងខ្មែរទាំងបរទេស។ ការជួបប្រទះជាមួយនិងទម្រង់សិល្បៈថ្មីជាកត្តាសំខាន់មួយដែលសិល្បករអាចរៀនសូត្របានប្រសើរ ហើយការស្វែងយល់ពីអ្វីថ្មីអាចជួយពង្រឹងជំនាញដែលមានស្រាប់។

## ជំនាញចាំបាច់៖ ជំនាញបច្ចេកទេសទូទៅ

សម្រាប់ជីវិតសិល្បករ ជំនាញសំខាន់បំផុតគឺប្រតិបត្តិក្នុងឯកទេសសិល្បៈរបស់ខ្លួន។ ក្រៅពីនេះ ការយល់ដឹងពីជំនាញបច្ចេកទេស (សម្លេង ពន្លឺ ។ល។) ទាក់ទងនឹងដំណើរការសម្តែង គឺជាគុណសម្បត្តិបន្ថែមក្នុងអាជីព។ សិល្បករប្រហែល៣០ភាគរយ មានសមត្ថភាពវាយតម្លៃថាប្រព័ន្ធនិងសម្លេងត្រូវបានរៀបចំបានល្អសម្រាប់ការសម្តែង។ ៨ភាគរយមានចំណេះធ្វើក្នុងការរៀបចំនិងចាត់ចែងសំឡេងលើឆាក និង៥ភាគរយមានជំនាញខាងរៀបចំពន្លឺ។ សិល្បករពាក់កណ្តាលទៀតយល់ថាខ្លួនពុំមានជំនាញក្នុងការងារបច្ចេកទេសពន្លឺនិងសំឡេងឡើយ។

### តួលេខទី១៤៖ ជំនាញបច្ចេកទេសទូទៅរបស់សិល្បករ




ចំពោះក្រុមសំណាកធុរជនសិល្បៈ (ដែលមានអ្នកបច្ចេកទេស ២៣ភាគរយ) ១០ភាគរយនៃពួកគេផ្តល់ចម្លើយថាពួកគេមានចំណេះធ្វើដើម្បីរៀបចំប្រព័ន្ធសំឡេងដែលមានភ្ជាប់ជាមួយឧបករណ៍អំភ្លីបាន ហើយ១៨ភាគរយទៀត អាចរៀបចំប្រព័ន្ធភ្លើង ព្រមទាំងភ្លេងនិងមេក្រូបាន។ ១៣ភាគរយផ្សេងទៀត អាចរៀបចំប្រព័ន្ធភ្លើង សម្រាប់ការសម្តែង ១២ភាគរយចេះថតសំឡេង និង២៧ភាគរយចេះថតវីដេអូ។ អ្នកបច្ចេកទេសមួយចំនួនស្នើសុំក្នុងចម្លើយរបស់ពួកគេនូវវគ្គបណ្តុះបណ្តាល អំពីវិស្វកម្មអគ្គីសនីសម្រាប់ពន្លឺនិងសំឡេងពេលសម្តែង (តម្លើងជួសជុលនិងថែរក្សា)។

យោងតាមលទ្ធផលជាតួលេខខាងលើនេះ សិល្បករអាចទទួលផលប្រយោជន៍ច្រើនពីការបណ្តុះបណ្តាល បន្ថែមក្នុងជំនាញបច្ចេកទេសដើម្បីធ្វើឲ្យកាន់តែប្រសើរជាងមុននូវការយល់ដឹងអំពីដំណើរការសម្តែងនិងគុណភាពនៃការសម្តែង។



កំពុងស្ថិតក្នុងដំណាក់កាលឈានមុខក្នុងជំនាញអាជីព ដោយសារសន្ទុះដ៏ខ្លាំងនៃការហាត់រៀន និងឆន្ទៈខ្ពស់របស់សិល្បករដែលចំណាយពេលវេលាយ៉ាងច្រើនគួរឲ្យកត់សម្គាល់ដើម្បីពង្រឹងជំនាញ។

## ៤. ការស្វែងយល់ពីយុទ្ធសាស្ត្រនិងបណ្តាញសិល្បៈ

ការធ្វើជាសិល្បករអាជីពត្រូវការជំនាញដ៏ចំណានក្នុងសិល្បៈ ហើយក្រៅពីនេះក៏ត្រូវការសមត្ថភាពក្នុងការផ្សព្វផ្សាយនិងរកទីផ្សារសម្រាប់ការសម្តែងទាំងមុនពេលនិងក្រោយពេលសម្តែង។ សិល្បករភាគច្រើនពុំមានលទ្ធភាពហិរញ្ញវត្ថុ ជួលអ្នកចាត់ការទូទៅសម្រាប់ជួយដល់ការងារនេះបានឡើយ។ ក្នុងលទ្ធផលទទួលបានមានសិល្បករខ្លះរក្សាទុកនូវសម្រង់រូបភាពផ្សេងៗខ្សែវីដេអូនិងអត្ថបទកាសែតដែលទទួលបានពីវណ្ណកម្មសិល្បៈរបស់ខ្លួន (សូមមើលតារាងតួលេខទី១៥)។

បណ្តាញទំនាក់ទំនងសិល្បករផ្តល់នូវឱកាសនៃការសម្តែង។ សិល្បករប្រមាណ៦៨ភាគរយ មានទំនាក់ទំនងជាមួយក្រុមសិល្បៈដ៏ទៃ។ ២៥ភាគរយទៀតជួយគ្នាទៅវិញទៅមកក្នុងការរកសិល្បករសម្តែងនៅពេលមានការសម្តែង។ សិល្បករ១៥ភាគរយទៀតផ្តល់ព័ត៌មានទំនាក់ទំនងសិល្បករដ៏ទៃទៀតដែលអាចជំនួសបានដល់អតិថិជននៅពេលពួកគេមិនអាចបំពេញការងារបាន។

### តួលេខទី១៥៖ ការរក្សាពត៌មានអំពីស្នាដៃសិល្បៈ




### ជំនាញចាំបាច់៖ យុទ្ធសាស្ត្រនិងបណ្តាញទំនាក់ទំនងទីផ្សារ

បើសិល្បករបានទទួលការបណ្តុះបណ្តាលអំពីវិធីសាស្ត្រក្នុងប្រើព័ត៌មានផ្សេងៗ ដែលពួកគេមាន យកមកជាគំរុយក្នុងការរៀបចំជាមធ្យោបាយផ្សព្វផ្សាយរកទីផ្សារ តាមរយៈបណ្តាញផ្សព្វផ្សាយប្រើប្រាស់ប្រព័ន្ធអ៊ិនធើណិត (Facebook, Youtube, ...) ។

បណ្តាញទំនាក់ទំនងដែលមានស្រាប់ អាចអភិវឌ្ឍបន្ថែមនិងផ្សាភ្ជាប់ជាមួយបណ្តាញអន្តរជាតិ ដើម្បីជួយសម្របសម្រួលទំនាក់ទំនងកាន់តែប្រសើររវាងក្រុមសិល្បករ។



## ៥. ពេលវេលាសម្តែង

**សិល្បករខ្មែរមាន សម្តែងជាចំនួន មធ្យម ៥៣ដង ក្នុងឆ្នាំ២០១៣**

ចំពោះក្រុមសំណាកភាគច្រើន ការសម្តែងជាសកម្មភាពការងារដែលនាំមកនូវចំណូល។ ដូច្នេះ ការវិភាគទៅលើបរិយាកាសការងារ ជាការសំខាន់មួយក្នុងការស្វែងយល់ពីបញ្ហាផ្សេងៗក្នុងវិស័យសិល្បៈ។

បើយើងវិភាគទៅលើចំនួនការសម្តែង យើងឃើញថាសិល្បករខ្មែរមានសម្តែងជាចំនួនមធ្យម៥៣ដងក្នុងឆ្នាំ២០១៣ (សូមមើលតារាងលេខ៣) ដែលស្មើនឹង១ដងក្នុង១សប្តាហ៍។

ទោះបីជាបានលទ្ធផលបែបនេះក្តី យើងត្រូវពិនិត្យយ៉ាងល្អិតល្អន់បន្ថែមទៀត។ យើងធ្វើការប្រៀបធៀបតួលេខចំនួនដងនៃការសម្តែងតាមផ្នែកសិល្បៈ។ យើងឃើញថាផ្នែកសៀកមានចំនួនដងនៃការសម្តែង ខ្ពស់ជាងផ្នែកដ៏ទៃទៀតខ្លាំង។ ដូចយើងបានបញ្ជាក់ពីខាងដើមក្នុងវិធីសាស្ត្រនៃសន្ទង់នេះ[១៣] សិល្បករផ្នែកសៀកដែលបានចូលរួមឆ្លើយសំណួរក្នុងសន្ទង់នេះ មកពីអន្តរអង្គភាពចំនួន២ គឺអង្គការហ្វារពន្លឺសិល្បៈដែលជាអង្គការក្រៅរដ្ឋាភិបាល និងសហគ្រាសហ្វារពន្លឺសិល្បៈដែលជាអាជីវកម្មសង្គម។ សម្រេសម្រួលមក អង្គការហ្វារពន្លឺសិល្បៈផ្តល់ការបណ្តុះបណ្តាលជំនាញសិល្បៈ ចំណែកឯសហគ្រាសហ្វារពន្លឺសិល្បៈផ្តល់មុខរបរនិងការងារសិល្បៈ។ អង្គភាពទាំង២នេះមានការចល័តនិងផ្លាស់ប្តូរសិល្បករគ្នាទៅវិញទៅមក។ ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក អង្គការហ្វារបានទ្រទ្រង់នូវវិស័យសិល្បៈ តាមរយៈការបង្ហាត់សិល្បៈ ដើម្បីឈានទៅរកការសម្តែងបែបអាជីព។ សិល្បករមួយចំនួនរបស់អង្គភាពនេះមានមុខរបរសម្តែងជារៀងរាល់ថ្ងៃក្នុងខេត្តសៀមរាប និងបាត់ដំបង ដែលមានចំនួនសរុបដល់ទៅ១១៧ដងក្នុង១ឆ្នាំ។ បើបែរជាមើលផ្នែកដ៏ទៃទៀតវិញ ផ្នែកតូរ្យតន្ត្រីនិងរបាំហាក់ដូចមានតួលេខចំនួនដងក្នុងការសម្តែងមិនលើសខ្វះគ្នាខ្លាំង គឺអ្នកភ្លេងនិងអ្នករបាំប្រហែល៥០ភាគរយមានការសម្តែងចំនួន១ដងទៅ២០ក្នុងមួយឆ្នាំ (សូមមើលតួលេខទី១៦)។ តែបើគិតជាមធ្យមវិញ អ្នករបាំមានសម្តែងចំនួន១០ដងច្រើនជាងអ្នកភ្លេងក្នុងមួយឆ្នាំ។ រីឯតួលេខផ្នែកល្ខោន សិល្បករប្រហែល៤០ភាគរយ បានសម្តែង៥១ទៅ១០០ដង និង៤០ភាគរយផ្សេងទៀតបានពី១ទៅ២០ដង។ ចំពោះធុរជនសិល្បៈដែលត្រូវធ្វើការងារពេលមានការសម្តែង (មាន៣៩ភាគរយនៃក្រុមសំណាក) មានការងាររៀបចំការចំនួនជាមធ្យម៦៤ដងក្នុងឆ្នាំ២០១៣។

### តារាងលេខ៣៖ ចំនួនការសម្តែងក្នុងឆ្នាំ២០១៣ រាយតាមផ្នែកសិល្បៈ

| ផ្នែកសិល្បៈ | ចំនួនដងនៃការសម្តែង |
|---|---|
| ល្ខោន | 47 |
| តូរ្យតន្ត្រី | 44 |
| សៀក | 117 |
| របាំ | 54 |
| បរិមាណមធ្យម | 53 |

### តារាងលេខ៤៖ ថេរៈវេលាមធ្យមនៃម៉ោងការងារសម្រាប់ការសម្តែងម្តង

| ផ្នែកសិល្បៈ | ថេរៈវេលា |
|---|---|
| ល្ខោន | 2h09 |
| តូរ្យតន្ត្រី | 2h51 |
| សៀក | 2h48 |
| របាំ | 2h53 |
| បរិមាណមធ្យម | 2h48 |

ចំពោះថេរៈវេលានៃការងារក្នុងការសម្តែងម្តងៗ[១៤] សិល្បករចំណាយពេលជិត៣ម៉ោងរាប់ចាប់តាំងពីពេលមកដល់រហូតដល់ពេលត្រឡប់ទៅផ្ទះវិញ។ យើងឃើញតួលេខនេះខុសគ្នាចំពោះសិល្បករសៀក ដែលថេរៈវេលានៃការងារសម្រាប់ការសម្តែងម្តងគឺប្រហែល២ម៉ោងប៉ុណ្ណោះ។ យើងអាចសន្និដ្ឋានបានថាការធ្វើការងារក្នុងបរិយាកាសការងារមានអាជីពខ្ពស់ជាមួយសិល្បករនិងអ្នកបច្ចេកទេសដែលមានការបណ្តុះបណ្តាលបានល្អ ដូចជាសិល្បករមកពីអង្គការហ្វារ នាំឲ្យថេរៈវេលាចំណាយលើការងារក្នុងការសម្តែងមានចំនួនតិចជាង។

### តួលេខទី១៦៖ ចំនួនការសម្តែងតាមទម្រង់សិល្បៈក្នុងឆ្នាំ២០១៣




### ជំនាញចាំបាច់៖ ជំនាញគ្រប់គ្រងការងារ

សិល្បករ២០ភាគរយនិងធុរជនសិល្បៈ៣២ភាគរយ ដើរតួនាទីជាប្រធានក្រុមសិល្បៈ។ តួនាទីនេះ គឺជាមុខងារសំខាន់មួយក្នុងវិស័យសិល្បៈទស្សនីយភាព។ អ្នកគ្រប់គ្រងទាំងឡាយត្រូវទទួលខុសត្រូវមើលដំណើរការរបស់ក្រុមទាំងមូលនិងប្រសិទ្ធិភាពការងារសិល្បៈ។ អ្នកគ្រប់គ្រងទាំងនេះជាញឹកញយគឺជាមេខ្យល់រាល់គ្រប់ការងារ ជាអ្នកទំនាក់ទំនងជាមួយអ្នកដ៏ទៃទៀត និងជាមើលខុសត្រូវលុយកាក់។ អ្នកគ្រប់គ្រងទាំងនេះជាអ្នកដោះស្រាយបញ្ហាបើមានទំនាស់ឬបញ្ហាអ្វីមួយក្នុងក្រុម។ ដោយសារភារកិច្ចជាអ្នកគ្រប់គ្រងនេះពួកគេផ្តល់នូវចម្លើយអំពីបញ្ហាក្នុងក្រុមទាក់ទងនិងបរិយាកាសការងារ ភាពយឺតយ៉ាវក្នុងការមកហាត់សមនិងការសម្តែង និងជម្លោះផ្សេងៗរវាងសិល្បករដែលបញ្ហាទាំងនេះកើតឡើងដដែលៗ ធ្វើឲ្យដំណើរការងារក្នុងក្រុមមិនសូវបានរលូនល្អ។ ការបណ្តុះបណ្តាលការគ្រប់គ្រងអាចជួយលើកកម្ពស់ប្រសិទ្ធិភាពខ្ពស់និងបង្កបរិយាកាសការងារល្អក្នុងសមាជិកក្រុម។ អ្នកគ្រប់គ្រងក្រុមទាំងនេះមានជំនាញខ្លះហើយ។ ការបំប៉នបន្ថែមជាមួយអ្នកជំនាញការគ្រប់គ្រង ពួកគេអាចរីកចម្រើនក្នុងការគ្រប់គ្រងក្រុមប្រកបដោយប្រសិទ្ធិភាពនិងភាពរលូននៅពេលមានបញ្ហា។ មានសិល្បករមួយចំនួនផ្តល់ចម្លើយថាក្នុងក្រុមរបស់ខ្លួនមានបញ្ហាក្នុងដឹកនាំមិនបានល្អ ហើយស្នើសុំឲ្យមានការបណ្តុះបណ្តាលក្នុងភាពជាអ្នកដឹកនាំ។

*១៣. សូមមើលអំពីអង្គការហ្វារ ក្នុង «ការបែងចែកក្រុមគំរូនិងកំណត់ចំណាំផ្សេងៗ»*
*១៤. ថេរៈវេលានៃការសម្តែងគឺជារយៈពេលរាប់ចាប់តាំងពីពេលមកដល់កន្លែងសម្តែងរហូតដល់ពេលត្រឡប់ទៅផ្ទះវិញ*

## ៦. ទីកន្លែងសម្តែង ទស្សនិកជន និង ការធ្វើដំណើរសម្តែង

ការសិក្សាទៅលើទីកន្លែងសម្តែងនាំឲ្យយើងបានដឹងអំពីអ្នកដែលជាអតិថិជនឬទស្សនិកជនសិល្បៈ។ ដូចដែលយើងអាចប៉ាន់ស្មានបានថាជាការធម្មតាសិល្បករ៣៧ភាគរយសម្តែងក្នុងពិធីមង្គលការដែលជាពិធីប្រពៃណីសំខាន់មួយក្នុងប្រទេសកម្ពុជា (សូមមើលតួលេខទី១៧)[១៥]។ ទីកន្លែងសម្តែងសិល្បៈសំដៅទីកន្លែងសម្តែងទាំងអស់ដែលជាទស្សនិកជនចូលមកសម្រាប់មើលការសម្តែងសិល្បៈផ្សេងៗ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ គឺសិល្បករ២៥ភាគរយសម្តែងនៅតាមភោជនីយដ្ឋាននិង១០ភាគរយសម្តែងនៅតាមសណ្ឋាគារក្នុងរយៈពេល៦ខែចុងក្រោយ។នេះបង្ហាញថាទោះបីសម្ព័ន្ធភាពការងាររវាងសិល្បករនិងអង្គការសមាគមក្រៅរដ្ឋាភិបាល[១៧]នៅខ្សោយនៅឡើយនិងមិនសូវមានចីរភាព។ យើងសង្កេតឃើញថាមានទំនាក់ទំនងសំខាន់មួយរវាងវិស័យសិល្បៈទស្សនីយភាពនិងវិស័យសេដ្ឋកិច្ច។

> **សិល្បករ២៥% សម្តែងនៅតាមភោជនីយដ្ឋាន និង ១០%សម្តែងតាមសណ្ឋាគារក្នុងរយៈពេល៦ខែចុងក្រោយ**

បើនិយាយអំពីការធ្វើដំណើរសម្តែងរបស់សិល្បករ សិល្បករប្រមាណ៥១ភាគរយធ្លាប់បានទៅសម្តែងនៅបរទេស ហើយ៧៦ភាគរយបានសម្តែងនៅក្រៅខេត្តក្រុងរបស់ខ្លួន។

សៀកគឺជាទម្រង់ដែលមានការធ្វើដំណើរសម្តែងច្រើនជាងគេក្នុងករណីទាំង២យ៉ាងនេះ[១៨]។ សិល្បកររបាំ និងតន្ត្រីករហាក់ដូចជាមានឱកាសសម្តែងនៅបរទេសបានច្រើនជាខេត្តក្រុងរបស់ខ្លួនដែលខុសពីសិល្បករផ្នែកល្ខោន។ បានជាយ៉ាងនេះ ព្រោះថាប្រភេទទស្សនិកជនមានភាពខុសគ្នាតាមទម្រង់សិល្បៈ។ ទម្រង់សិល្បៈដូចជាល្ខោនបាសាក់មានប្រជាប្រិយភាពក្នុងស្រទាប់មហាជនខ្មែរច្រើនជាងគេ។ ហេតុនេះសិល្បករល្ខោនជាច្រើនដែលយើងបានជួប សម្តែងតែនៅតាមជនបទពាសពេញផ្ទៃស្រុកខ្មែរ។ ទេសចរណ៍ គឺជាវិស័យមួយដែលសំខាន់បំផុតក្នុងសេដ្ឋកិច្ចក្នុងបច្ចុប្បន្នភាពរបស់កម្ពុជា។ ក្នុងឆ្នាំ២០១៣ទេសចរចំនួន៤.២០០.០០០នាក់មកពីជុំវិញពិភពលោកមកទស្សនាព្រះរាជាណាចក្រនេះនិងទីដ្ឋានវប្បធម៌ទាំងឡាយក្នុងប្រទេស[១៩]។ សម្រាប់វិស័យសិល្បៈបរិមាណភ្ញៀវទេសចរបង្កើតនូវទីផ្សារយ៉ាងសំខាន់មួយសម្រាប់ការសម្តែងនិងផ្សព្វផ្សាយសិល្បៈខ្មែរទៅកាន់ពិភពលោក និងជាប្រភពចំណូលមួយយ៉ាងធំគួរឲ្យកត់សម្គាល់។ អាស្រ័យហេតុនេះហើយ សិល្បករខ្មែររហូតដល់ទៅ ៩០ភាគរយ សម្តែងសិល្បៈរបស់ខ្លួនសម្រាប់ទស្សនិកជនបរទេស។

### ការភ័យខ្លាចក្នុងការធ្វើដំណើរ៖

សិល្បករបានផ្តល់ចម្លើយនៃការភ័យខ្លាចក្នុងការធ្វើចរាចរណ៍។ ពួកគេត្រូវធ្វើដំណើរទៅកាន់ទីកន្លែងសម្តែង។ ដោយសារបញ្ហាសុវត្ថិភាពចរាចរណ៍[១៦] ពួកគេជាច្រើនមានការភ័យខ្លាចនូវគ្រោះថ្នាក់ចរាចរណ៍ដែលអាចកើតឡើង។

### តួលេខទី១៧៖ ទីកន្លែងសិល្បករសម្តែងក្នុងរយៈពេល៦ខែចុងក្រោយ




### ជំនាញចាំបាច់៖ ជំនាញភាសាបរទេស

ដោយសារចំនួនជនបរទេសមានបរិមាណខ្ពស់ក្នុងវិស័យសិល្បៈទស្សនីយភាពខ្មែរ (ទស្សនិកជន ការបណ្តុះបណ្តាល សិក្ខាសាលា អង្គការសមាគមមិនមែនរដ្ឋាភិបាល។ល។) ភាសាបរទេសបានក្លាយជាជំនាញមួយយ៉ាងសំខាន់សម្រាប់សិល្បករនិងធុរជនសិល្បៈដែលមានបំណងចង់អភិវឌ្ឍក្នុងអាជីពរបស់ខ្លួន។ ដូច្នេះ សិល្បករនិងធុរជនសិល្បៈ៨៦ភាគរយបានបញ្ជាក់ថាពួកគេត្រូវការជំនាញភាសាអង់គ្លេសជាផ្នែកមួយនៃជីវភាពអាជីពសិល្បៈរបស់ពួកគេ ហើយពួកគេមួយចំនួនបានស្នើសុំឲ្យមានការបណ្តុះបណ្តាលផ្នែកភាសា។ បើយើងសិក្សាទៅលើជំនាញភាសាដែលមានស្រាប់របស់ពួកគេ សិល្បករប្រមាណ៥០ភាគរយមិនអាចនិយាយភាសាអង់គ្លេសបានល្អ ហើយ៥០ភាគរយទៀតអាចប្រើប្រាស់ភាសាអង់គ្លេសក្នុងកម្រិតទំនាក់ទំនងបាន។ គ្មាននរណាម្នាក់ក្នុងក្រុមសំណាកសិល្បករផ្តល់ចម្លើយថានិយាយភាសាអង់គ្លេសបានពូកែនោះទេ។ ចំណែកឯធុរជនសិល្បៈមានកម្រិតភាសាអង់គ្លេសខ្ពស់ជាងបន្តិច ដោយសារកម្រិតវប្បធម៌របស់ពួកគេខ្ពស់ជាងផងដែរ ប៉ុន្តែក៏នៅតែមាន៣៨ភាគរយនៃធុរជនសិល្បៈអត់ចេះភាសាអង់គ្លេសសោះតែម្តង។

### តួលេខទី១៨៖ កម្រិតភាសាអង់គ្លេស




*១៥. សំណួរផ្តោតលើរយៈពេល៦ខែចុងក្រោយពេលក្នុងពេលអនុវត្តសន្ទង់នេះ*
*១៦. សម្រាប់ព័ត៌មានបន្ថែម សូមមើល «របាយការណ៍ស្ថានភាពសកលនៃសុវត្ថិភាពចរាចរណ៍ ឆ្នាំ២០១៣» របស់អង្គការសុខភាពពិភពលោក*
*១៧. សូមមើល តួលេខទី៩ «ប្រភេទស្ថាប័នឬអង្គភាព»*
*១៨. សំណួរនេះបានសួរសម្រាប់រយៈពេល៦ខែចុងក្រោយនៃពេលអនុវត្តសន្ទង់*
*១៩. សូមមើលអំពីអង្គការហ្វារ ក្នុង «ការបែងចែកក្រុមគំរូនិងកំណត់ចំណាំផ្សេងៗ»*



III

# ស្ថានភាពសេដ្ឋកិច្ច

ភាគនេះនៃរបាយការណ៍សន្ទង់ សិក្សាទៅលើស្ថានភាពសេដ្ឋកិច្ច
នៃសិល្បករនិងធុរជនសិល្បៈ ។

## ១. ប្រាក់កំរៃសម្តែង

ដូចដែលបានបរិយាយពីខាងលើ ការសម្តែងចំណូលចម្បងក្នុងជីវភាពរស់នៅរបស់សិល្បករ។ អ៊ីចឹងហើយ សន្ទង់នេះបានរកឃើញថាប្រាក់កំរៃមធ្យមរបស់ការសម្តែងម្តងគឺ២១ដុល្លារអាមេរិចក្នុងសិល្បករម្នាក់។ សិល្បករសៀកទទួលបានប្រាក់កំរៃខ្ពស់ជាងគេ[២០] ហើយសម្រាប់សិល្បករនៃទម្រង់សិល្បៈដ៏ទៃផ្សេងទៀត យើងសង្កេតឃើញប្រាក់ចំណូលរបស់ពួកគេល្មៀងគ្នាច្រើនបំផុតប្រហែល២,៥ដុល្លារអាមេរិច។ បើយើងយកថេរៈវេលាធ្វើការក្នុងការសម្តែងម្តងៗ យើងបានធ្វើប្រមាណវិធីរកប្រាក់កំរៃសម្តែងក្នុង១ម៉ោង (សូមមើលតារាងលេខ៥)។ លទ្ធផលបង្ហាញថា សិល្បករទទួលចំណូលប្រចាំម៉ោងពី៦ទៅ៧ដុល្លារ លើកលែងតែសិល្បករសៀកដែលទទួលបាន១៤ដុល្លារក្នុង១ម៉ោង។

> សិល្បករទទួល ចំណូលប្រហែល **៧**ដុល្លារអាមេរិច ក្នុង១ម៉ោងមកពី ការសម្តែង

បើយើងវិភាគលើតួលេខ(ក្នុងតួលេខទី១៩) យើងអាចសង្កេតឃើញថាក្នុងផ្នែករបាំសិល្បករ២២ភាគរយ រកប្រាក់កំរៃបានតិចជាង៥ដុល្លារក្នុងការសម្តែងមួយ ដែលមានភាពទាបជាងខ្លាំង បើធៀបនឹងទម្រង់សិល្បៈផ្សេងៗទៀត។ សិល្បករមកពីសៀមរាបប្រមាណ៧៥ភាគរយសម្តែងភាគច្រើនក្នុងសណ្ឋាគារ ឬភោជនីយដ្ឋានដែលផ្តល់នូវស្ថានភាពមួយដោយឡែកពីគេ។ ចំពោះល្ខោននិងតូរ្យតន្ត្រី តួលេខបង្ហាញថាប្រាក់កំរៃទាបមានចំនួនតិច ប៉ុន្តែសិល្បករជាច្រើនក្នុងទម្រង់ទាំង២នេះទទួលបានកំរៃ ពី១០ទៅ២០ដុល្លារ (៤៣ភាគរយនៃអ្នកភ្លេង និង៥៤ភាគរយនៃតួត្លុកក្នុងល្ខោន)។ រីឯសៀក មានតែសិល្បករ១០ភាគរយប៉ុណ្ណោះរកកំរៃសម្តែងតិចជាង១០ដុល្លារ ហើយសិល្បករប្រមាណ៦០ភាគរយរកបានពី១០ទៅ២០ដុល្លារ។

លើសពីនេះ ពេលសិល្បករមានការសម្តែង ពួកគេក៏មានកាតព្វកិច្ចចំណាយផ្សេងៗទៀតសម្រាប់ការសម្តែងនោះ។ យើងអាចឃើញសិល្បករភាគច្រើនត្រូវទទួលបន្ទុកចំណាយនេះនោះ ដែលទាក់ទងនិងការសម្តែងមួយ។ ឧទាហរណ៍ សិល្បករ៦១ភាគរយត្រូវចំណាយលើ ការធ្វើដំណើររបស់ខ្លួន និង៥៨ភាគរយចំណាយលើអាហារដែលទាំង២នេះជាចំណាយចម្បងពេលមានការសម្តែងម្តងៗ។ គួរឲ្យសោកស្តាយយើងមិនបានប្រមូលព័ត៌មានស៊ីជម្រៅជាងនេះទៀត ដើម្បីវាយតម្លៃលើចំណាយជាក់ស្តែងទាំងនេះនិងគណនារកចំណូលជាក់ស្តែងដែលសិល្បករពិតជាទទួលបាន។

និយាយអំពីធុរជនសិល្បៈវិញម្តង ពេលធ្វើការងារក្នុងពេលសម្តែង យើងបានលទ្ធផលថាប្រាក់កំរៃមធ្យមរបស់ពួកគេខ្ពស់ជាងសិល្បករ គឺពួកគេទទួលបាន៣៤ដុល្លារអាមេរិចក្នុងមួយការសម្តែង។ បើយើងមើលលំអិតក្នុងចំណុចនេះអ្នកចាត់ការទូទៅរបស់សិល្បករទទួលបានប្រាក់កំរៃខ្ពស់ជាងគេគឺ៤៧ដុល្លារអាមេរិច បន្ទាប់មកគឺអ្នកគ្រប់គ្រងបច្ចេកទេសនិងអ្នករដ្ឋបាលសិល្បៈ។ តួលេខដ៏ខ្ពស់នេះ គឺទទួលបានពីធុរជនសិល្បៈមួយចំនួនដែលយើងអាចទាក់ទងដល់ពួកគេក្នុងបណ្តាញការងាររបស់ពួកយើង ក្នុងការជួយសហការផ្តល់ចម្លើយក្នុងសន្ទង់នេះ។

### តួលេខទី១៩៖ ប្រាក់កំរៃសម្តែងតាមទម្រង់




### តារាងលេខ៦៖ ប្រាក់កំរៃរបស់ធុរជនសិល្បៈក្នុងការសម្តែងម្តង

| មុខងារ | ទឹកប្រាក់ |
|---|---|
| អ្នករដ្ឋបាល អ្នកគ្រប់គ្រង | $26 |
| អ្នកបច្ចេកទេស | $31 |
| អ្នកគ្រប់គ្រងសិល្បករ | $47 |
| មធ្យមភាគ | $34 |



### តារាងលេខ៥៖ ការវិភាគប្រាក់កំរៃការសម្តែងធៀបនឹងថេរៈវេលាសម្តែង

| | ថេរៈវេលាមធ្យម ក្នុងការសម្តែងម្តង | ប្រាក់កំរៃមធ្យម ក្នុងការសម្តែងម្តង | ប្រាក់កំរៃទទួលបាន ក្នុងមួយម៉ោង |
|---|---|---|---|
| សៀក | 2h09 | $31 | $14 |
| របាំ | 2h51 | $17 | $6 |
| តូរ្យតន្ត្រី | 2h48 | $20 | $7 |
| ល្ខោន | 2h53 | $19 | $6 |
| មធ្យមភាគ | 2h48 | $21 | $7 |

### ជំនាញគ្រប់គ្រងថវិកា

សិល្បករក្នុងសន្ទង់នេះដូចជាមិនផ្តោតលើចំណាយចំណូលក្នុងការសម្តែងណាមួយនោះឡើយ។ ពួកគេភាគច្រើនផ្តល់ចម្លើយថាមានចំណាយផ្សេងៗក្នុងការសម្តែង តែពួកគេពុំបានស្នើសុំនូវការបង់ប្រាក់លើចំណាយទាំងនោះវិញទេ។ ជាការល្អមួយបើយើងអាចសិក្សាអំពីជំនាញគ្រប់គ្រងថវិការបស់សិល្បករ ហើយប្រើលទ្ធផលទទួលបានរៀបចំជាការបណ្តុះបណ្តាលផ្នែកនេះ ។

២០. របាយការណ៍ស្ថិតិ ឆ្នាំ២០១៣ ក្រសួងទេសចរណ៍

## ២. ចំណូលប្រចាំខែ

ដូចបានរៀបរាប់ពីមុនមក ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិល្បករ ប្រាក់កំរៃបានមកពីការសម្តែងគឺជាបេះដូងសេដ្ឋកិច្ចស្នូលរបស់ពួកគេ។ យើងបានវិភាគនៅខាងលើអំពីការងារសម្តែង ថេរៈវេលា និងប្រាក់កំរៃ ដាច់ដោយឡែកពីគ្នា។ បើយើងយកការវិភាគខាងលើទាំងនេះមកសំយោគចូលគ្នាយើងអាចប៉ាន់ប្រមាណនូវចំណូលប្រចាំខែដែលបានមកពីការសម្តែង។ ហេតុនេះ យើងឃើញចំណូលមធ្យមសម្រាប់សិល្បករសៀកមានច្រើនបង្គួរ[២១]។

**សិល្បករទទួលបាន ៩២ដុល្លារ ក្នុងមួយខែ សកម្មភាពសម្តែង**

បើយើងដកសិល្បករសៀកចេញ យើងនឹងឃើញចំណូលមធ្យមរបស់សិល្បករទម្រង់ល្ខោន តូរ្យតន្ត្រី និងរបាំមានលំដាប់ពី៧៣ដល់៨០ដុល្លារក្នុងមួយខែ។ សូមមើលតួលេខទី២០ដើម្បីជ្រាបពីទិន្នន័យចំណូលប្រចាំខែរបស់សិល្បករ។ សិល្បករ៥២ភាគរយរកចំណូលបានក្រោម១០០ដុល្លារក្នុងមួយខែ។

យើងអាចសង្កេតឃើញថា ធុរជនសិល្បៈមានប្រាក់ចំណូលជាមធ្យមខ្ពស់ជាងសិល្បករ។ ចំណូលជាមធ្យមពីវិស័យសិល្បៈគឺ២៧៤ដុល្លារអាមេរិចក្នុងមួយខែ។ មានធុរជនសិល្បៈតែប្រហែល២៤ភាគរយទេ ដែលរកចំណូលបានក្រោម១០០ដុល្លារអាមេរិចក្នុងមួយខែ ៣២ភាគរយរកបានពី១០០ទៅ២០០ដុល្លារអាមេរិច និងភាគច្រើនពួកគេរកបាន២០០ដុល្លារអាមេរិចក្នុងមួយខែ (សូមមើលតួលេខទី២១)។ អ្នកបច្ចេកទេសរកចំណូលបាន២១៥ដុល្លារអាមេរិច ក្នុងមួយខែដែលបរិមាណទាបជាងគេ និងបន្ទាប់មកគឺបុគ្គលិករដ្ឋបាលសិល្បៈដែលរកចំណូលបានប្រហែល២៨៥ដុល្លារអាមេរិច។ អ្នកគ្រប់គ្រងក្រុមសិល្បកររកចំណូលបានខ្ពស់ជាងគេគឺ៣០២ដុល្លារក្នុងមួយខែ។

### តារាងលេខ៧៖ ចំណូលមធ្យមប្រចាំខែពីការសម្តែងក្នុងឆ្នាំ២០១៣

| ទម្រង់ | ចំណូល |
|---|---|
| ល្ខោន | $73 |
| តូរ្យតន្ត្រី | $73 |
| សៀក | $305 |
| របាំ | $80 |
| មធ្យមភាគ | $92 |

### តារាងលេខ៨៖ ចំណូលមធ្យមប្រចាំខែនៃធុរជនសិល្បៈឆ្នាំ២០១៣

| មុខងារ | ចំណូល |
|---|---|
| អ្នករដ្ឋបាល អ្នកគ្រប់គ្រង | $285 |
| អ្នកបច្ចេកទេស | $215 |
| អ្នកគ្រប់គ្រងសិល្បករ | $302 |
| មធ្យមភាគ | $274 |

**សិល្បករ៥២%រកចំណូលបានក្រោម១០០ដុល្លារក្នុងមួយខែ**

តួលេខទី២០៖ ចំណូលសរុបប្រចាំឆ្នាំរបស់សិល្បករក្នុងឆ្នាំ២០១៣




តួលេខទី២១៖ ចំនូលមធ្យមប្រចាំខែនៃធុរជនសិល្បៈឆ្នាំ២០១៣




## ៣. ស្ថានភាពការងារមិនមានស្ថេរភាព

លក្ខណៈមួយនៃជីវភាពរបស់សិល្បករគឺការឡើងចុះនៃបរិមាណការងារ។ យើងដឹងថា សិល្បករភាគច្រើនសម្តែងឲ្យទស្សនិកជនបរទេសដែលសឹងតែទាំងអស់ជាភ្ញៀវទេសចរ។ កត្តា១នេះនាំឲ្យមុខរបររបស់ពួកគេពឹងផ្អែកផ្ទាល់ ទៅលើលំហូរចូលនៃភ្ញៀវទេសចរនិងអាស្រ័យទៅលើខែមួយចំនួននៃឆ្នាំដែលជារដូវល្អសម្រាប់ការងារនេះ។

កត្តាទី២ ដែលទាក់ទងនិងកត្តាទី១ គឺរដូវវស្សាដែលគេចាត់ទុកថាជារដូវទាបទាំងមង្គលការនិងទាំងទេសចរណ៍។ ខ្សែកោងទាំង២ក្នុងតួលេខទី២២[២២] ខាងលើបង្ហាញពីបម្រែបម្រួលចំណូលមធ្យមក្នុងឆ្នាំ២០១៣។ បម្រែបម្រួលនេះកើតឡើងក្នុង២រដូវ៖ រដូវទាបចាប់ពីខែមេសាដល់តុលា ដែលភាគច្រើននៃកំឡុងពេលនេះជារដូវវស្សា និងរដូវខ្ពស់ដែលជាខែផ្សេងៗទៀត និងខ្ពស់បំផុតក្នុងខែធ្នូ។ ទន្ទឹមនិងនេះ រដូវមង្គលការក្នុងប្រទេសកម្ពុជាក៏បិតក្នុងខែធ្នូនេះដែរ។ ការងារនេះទីពឹងទៅលើកត្តាទាំង២នេះ ហេតុនេះមិនផ្តល់នូវស្ថេរភាពសេដ្ឋកិច្ចរស់នៅដល់សិល្បករនោះឡើយ ហើយនាំឲ្យជីវភាពរបស់ពួកគេមិនមានភាពឋិតថេរបើពួកគេមិនមានមធ្យោបាយទៅរកប្រភពចំណូលផ្សេងទៀតទេនោះ។

*២១. សូមមើលអំពីអង្គការហ្វារ ក្នុង «ការបែងចែកក្រុមគំរូនិងកំណត់ចំណាំផ្សេងៗ»*
*២២. តួលេខជាលទ្ធផលនេះ ទទួលបានដោយសារសិល្បករផ្តល់ចម្លើយដោយគូសជ្រើសរើសខែណាដែលពួកគេរកប្រាក់ចំណូលបាន ខ្ពស់ជាងគេនិងខែណាដែលបានទាបជាងគេ*

**តួលេខទី២២៖ បម្រែបម្រួលប្រាក់ចំណូល ឆ្នាំ២០១៣**




## ៤. ចំណូលបំពេញបន្ថែមនិងការគាំទ្រជីវភាពរស់នៅ

ស្ថានភាពមិនបិតបេរនិងប្រាក់កំរៃទាបក្នុងការងារនាំឲ្យសិល្បករមួយចំនួនរកមធ្យោបាយផ្សេងៗដើម្បីទ្រទ្រង់ជីវភាព។ ដូច្នេះហើយសិល្បករ៣៣ភាគរយមានការងារបន្ថែម១ទៀតក្រៅពីសិល្បៈដើម្បីជាការបំពេញបន្ថែមនូវចំណូល។ ពួកគេភាគច្រើនរកចំណូលបន្ថែមនោះ តាមការងារពលកម្មដូចជាកសិករ និងកម្មករសំណង់ជាដើម (សូមមើលតួលេខ២៣) និង៣៣ភាគរយទៀតជាអ្នករកស៊ីឬអាជីវករ។

សិល្បករ៤៧ភាគរយដែលមានការជាមួយទៀត នៅតែធ្វើការក្នុងសិល្បៈអស់ចំនួន៧៥ភាគរយនៃពេលវេលារបស់ពួកគេ។ ជាទូទៅការងារបំពេញបន្ថែមនេះ មិនស៊ីពេលវេលារបស់ពួកគេអស់ជាងពាក់កណ្ដាលនោះទេ តែមានសិល្បករ២៥ភាគរយដែរដែលចំណាយពេលអស់តែ ២៥ភាគរយប៉ុណ្ណោះក្នុងការងារសិល្បៈ។ តួលេខទាំងអស់នេះ គឺជាតួលេខមធ្យមនិងអាស្រ័យតាមខែខ្លះនៃរដូវទាបឬខ្ពស់ក្នុងការងារសិល្បៈ។ យើងអាចទស្សន៍ទាយបានថាការងារបំពេញបន្ថែមមានភាពសំខាន់នៅក្នុងអំឡុងពេលរដូវវស្សា។ បើក្រលេកមកមើលធុរជនសិល្បៈវិញពួកគេ៤០ភាគរយមានការងារបន្ថែម។ ខុសគ្នាពីសិល្បករ ធុរជនភាគច្រើន មានការងារបន្ថែមជាអ្នករកស៊ី បើកហាងឬអាជីវកម្មផ្ទាល់ខ្លួន ហើយមានតែ១៧ភាគរយនៃពួកគេទេ ដែលធ្វើការងារកម្លាំងពលកម្មក្នុងការងារបន្ថែម (សូមមើលតួលេខទី២៤)។

ម៉្យាងវិញទៀត យើងសង្កេតឃើញថាសិល្បករនិងធុរជនសិល្បៈមួយចំនួនបានបងប្អូនសាច់ញាតិជួយឧបត្ថម្ភគាំទ្រ (សូមមើលតួលេខទី២៥)។ សិល្បករ៦៤ភាគរយបានបងប្អូនសាច់ញាតិជួយក្នុងការរស់នៅ។ ដូចដែលយើងបានដឹងថាក្រុមសំណាកក្នុងសន្ទង់នេះមានយុវជនជាច្រើនដែលនៅលីវ។ សិល្បករជាច្រើននៅរស់នៅជាមួយឪពុកម្ដាយ និងបានឪពុកម្ដាយចិញ្ចឹមដូចយុវជនដ៏ទៃទៀតដែរ។ ធុរជនសិល្បៈដោយសារមានលំដាប់អាយុខ្ពស់ជាងនិងមានចំណូលច្រើនជាង ពួកគេត្រូវការជំនួយពីគ្រួសារតិចជាង។ តួលេខបង្ហាញថា មានតែ៣៣ភាគរយប៉ុណ្ណោះដែលទទួលជំនួយជីវភាពពីបងប្អូនសាច់ញាតិ។

ប្រមែប្រមូលទិន្នន័យខាងលើនេះបញ្ចូលគ្នា យើងទទួលបាននូវទិដ្ឋភាពទូទៅមួយនៃស្ថានភាពសិល្បករ។ តួលេខទី២៦ បកស្រាយនូវជីវភាពការងារជាមធ្យមប្រចាំថ្ងៃមួយ[២៣]។ វដ្តនេះបង្ហាញពីសកម្មភាព ចម្បងក្នុងជីវភាពរបស់

**៣៣%នៃពួកគេមានការងារផ្សេងពីសិល្បៈដើម្បីបំពេញចំណូលបន្ថែម**

**តួលេខទី២៣៖ ការងារបំពេញបន្ថែមចំណូលរបស់សិល្បករ**




**តួលេខទី២៤៖ ការងារបំពេញបន្ថែមចំណូលរបស់ធុរជនសិល្បៈ**




*២៣. ចំនុចនេះត្រូវការការវិភាគដោយយកអត្រាភាគរយនៃទិន្នន័យផ្សេងៗទៀតពីខាងលើ*



**តួលេខទី២៥៖ ជំនួយចិញ្ចឹមជីវិតទទួលពីគ្រួសារ**




សិល្បករ។ ក្នុងប្រអប់ពណ៌លឿង យើងអាចឃើញសកម្មភាពដែលគ្មានចំណូល និងក្នុងប្រអប់ពណ៌បៃតងសកម្មភាពដែលមានចំណូល។

សកម្មភាពការងារទាំងឡាយក្នុងវដ្តខាងលើនេះ អាចឲ្យយើងដឹងថាប្រាក់ចំណូលដែលសិល្បករអាចទទួលបានប្រចាំខែគឺ៩២ដុល្លារអាមេរិច។ ការងារបង្ហាត់សិល្បៈផ្តល់ប្រាក់កំរៃចំនួន៨០ដុល្លារអាមេរិច (តួលេខ ប្រាក់ចំណូលអង្គកណ្តាល) និងសិល្បករ៣៣ភាគរយផ្សេងទៀតមានការងារផ្សេងដើម្បីបន្ថែមប្រាក់ចំណូល។ សិល្បករប្រមាណ៥២ភាគរយរកថវិកាបានតិចជាង១០០ដុល្លារអាមេរិចក្នុងមួយខែ និង២០ភាគរយរកបានពី១០០ទៅ២០០ដុល្លារពីការងារ។ បើធៀបនឹងវិស័យការងារដ៏ទៃផ្សេងទៀតប្រាក់ខែរបស់កម្មករក្នុងឧស្សាហកម្មកាត់ដេរ គឺមានចំនួន៩៥ដុល្លារអាមេរិច[២៤] គ្រូបង្រៀន៨៨ដុល្លារ កម្មករសំណង់៨៣ដុល្លារ និងមន្ត្រីរាជការ១១៨ដុល្លារអាមេរិច[២៥]។

**តួលេខទី២៦៖ គំរូជីវភាពប្រចាំសប្តាហ៍មួយនៃសិល្បករ**




*២៤. សម្រង់ពីគេហទំព័រ http://www.business-humanrights.org/Documents/Cambodia-garment-workers-crackdown*

*២៥. ទិន្នន័យនេះមានមូលដ្ឋានលើសន្ទង់ប្រាក់បៀវត្ស ដោយវិទ្យាស្ថាន Cambodia Institute of Development Study and Wage Indicator Foundation ដែលបានធ្វើពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០១១ ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១ នៅទីក្រុងភ្នំពេញ និងទីរួមខេត្តចំនួន៤ផ្សេងទៀត (បាត់ដំបង កំពង់ចាម ព្រះសីហនុ និងសៀមរាប)*

## ៥. ស្ថានភាពការងារវិភាគតាមការបែងចែកក្រុមផ្សេងៗទៀត

### ក. សមភាពយេនឌ័រ (វិសមភាពនៃប្រាក់ចំណូល)

នៅក្រុងព្រះរាជាណាចក្រកម្ពុជា ច្បាប់ការងារបានចែងថា៖ កម្មករទាំងអស់មានសិទ្ធិស្មើគ្នា និងមិនត្រូវទទួលការរើសអើងពីមជ្ឈដ្ឋានណាមួយដោយសារភេទ ជនជាតិ សាសនា ។ល។ នោះឡើយ។ ការទទួលបានប្រាក់កំរៃស្មើគ្នា សម្រាប់ការងារដែលមានវិសាលភាពដូចគ្នា គឺគោលការណ៍ទូទៅមួយមានចែងក្នុងច្បាប់។ការផ្តល់ប្រាក់កំរៃការងារខុសគ្នាទៅតាមភេទ អាយុ ដើមកំណើតរបស់និយោជិត ត្រូវបានហាមឃាត់។ ទោះបីជាយ៉ាងនេះក្តី ការរើសអើងនេះនៅតែមានហើយជាឧបសគ្គរាំងដល់ដំណើរការអភិវឌ្ឍ[២៦]។ សន្ទង់មួយក្នុងវិស័យមុខរបរនិងការងារត្រូវបានធ្វើឡើងដែលផ្តល់លទ្ធផលថា មានគម្លាតប្រាក់កំរៃចំនួន២៥ដុល្លារក្នុង១ខែរវាងបុរសនិងស្ត្រី[២៧]។ ដូច្នេះ សមភាពយេនឌ័រ គឺជាកត្តាគន្លឹះមួយក្នុងវឌ្ឍនភាពសិល្បៈទស្សនីយភាពខ្មែរដែលគួរសិក្សា។ បើក្រឡេកមើលលើការបណ្តុះបណ្តាលផ្នែកសិល្បៈ យើងមិនឃើញមានការរើសអើងនោះទេ ហើយសិល្បករទាំង២ភេទមានឱកាសស្មើគ្នាក្នុងការសិក្សាផ្នែកសិល្បៈ។

**ស្ត្រីធ្វើការច្រើនជាងបុរស២០នាទី ក្នុងការសម្តែង១ តែទទួលប្រាក់កំរៃបានតិចជាងបុរស ២ដុល្លារអាមេរិច**

នៅពេលដែលធ្វើការប្រៀបធៀបគ្នា សន្ទង់នេះបង្ហាញថាប្រាក់កំរៃសម្តែងរបស់ស្ត្រី មានកម្រិតទាបជាងបុរស។ បើគិតជាមធ្យម ស្ត្រីធ្វើការច្រើនជាងបុរស២០នាទី ក្នុងការសម្តែង១ តែទទួលប្រាក់កំរៃបានតិចជាងបុរស ២ដុល្លារអាមេរិចទៅវិញ។ តួលេខក្រៅពីនេះគឺ ស្ត្រីមានការសម្តែងចំនួន៥០ដងជាមធ្យមក្នុងឆ្នាំ២០១៣ ឯបុរសមានចំនួន៥៦ដង។ នេះបើសរុបជាមធ្យមភាគប្រចាំសប្តាហ៍ ទាំងបុរសទាំងស្ត្រី ធ្វើការចំនួន៣ម៉ោងក្នុងមួយសប្តាហ៍។

ស្ត្រីរកប្រាក់កំរៃពីការសម្តែងបានចំនួន៧៥ដុល្លារអាមេរិច រីឯបុរសបានចំនួន១០១ ដុល្លារអាមេរិចដែលនេះបង្ហាញនូវគម្លាតប្រាក់កំរៃចំនួន ២៥ដុល្លារ អាមេរិចរវាងបុរសនិងស្ត្រី ដូចកម្មកររោងចក្រដែរ ។ ចំពោះធុរជនសិល្បៈវិញ គម្លាតនេះ មានភាពកាន់ធំជាងព្រោះលទ្ធផលបញ្ជាក់ថាស្ត្រីទទួលប្រាក់កំរៃការងារជាមធ្យមបានចំនួន២០៤ដុល្លារអាមេរិច និងបុរសបានចំនួន៣២៧ដុល្លារអាមេរិច។

កត្តាវិសមភាគនៃប្រាក់ចំនូលនេះ នាំឲ្យស្ត្រីត្រូវការការឧបត្ថម្ភគាំទ្រពីក្រុមគ្រួសារច្រើនជាងបុរស (តួលេខ គឺស្ត្រី៧៣ភាគរយត្រូវការការជួយពីគ្រួសារធៀបនិងបុរសមានចំនួន៥៩ភាគរយ)។ ហេតុនេះ ស្ត្រីមានឱកាសនៃការព្យាយាមរស់នៅដោយមិនមានការពឹងផ្អែកផ្នែកសេដ្ឋកិច្ចលើអ្នកដ៏ទៃទាបជាងបុរស។

**សមភាពយេនឌ័រ**

គំនិតផ្តួចផ្តើមឲ្យមានការជជែកពិភាក្សាអំពីសមភាពយេនឌ័រ គឺជាការសំខាន់មួយ ដើម្បីជាការស្វែងរកដំណោះស្រាយក្នុងការបង្កើនសមភាពនេះ និងផ្តល់នូវឱកាសស្មើគ្នាដល់បុរសនិងស្ត្រីក្នុងការអភិវឌ្ឍអាជីពរបស់ខ្លួន ។

**តារាងលេខ៩- ការប្រៀបធៀបតាមយេនឌ័រ**

| | បុរស | ស្ត្រី | សរុប |
|---|---|---|---|
| ថេរៈវេលាការងារក្នុងការសម្តែងម្តង | 1h40 | 3h01 | 2h48 |
| ប្រាក់កំរៃក្នុងការសម្តែងម្តង | $21,8 | $18 | $21 |
| ប្រាក់កំរៃក្នុងមួយម៉ោង | $8,1 | $5,9 | $7 |
| ចំនួនដងនៃការសម្តែង | 56 | 50 | 53 |
| ចំនួនម៉ោងសម្តែងក្នុង១សប្តាហ៍ | 3h06 | 3h08 | 2h48 |
| ប្រាក់កំរៃទទួលបានក្នុង១ខែ | $101 | $75 | $92 |

**តួលេខទី២៧៖ ទស្សនៈអនាគតកាលអំពីអាជីពសិល្បៈរបស់ស្ត្រី**




**តួលេខទី២៨៖ ទស្សនៈអនាគតកាលអំពីអាជីពសិល្បៈរបស់បុរស**




ទាក់ទិនទៅនឹងទស្សនៈអនាគតកាលអំពីអាជីពសិល្បៈ ស្ត្រីបញ្ចេញមតិតិចជាងបុរស (សូមមើលតួលេខទី២៧និង២៨)។ ស្ត្រី៣៧ភាគរយចង់បន្តអាជីពជាសិល្បករអស់មួយជីវិត (បុរស៥៧ភាគរយ) ស្ត្រី៤៩ភាគរយមិនច្បាស់លាស់អំពីអនាគតជីវិតសិល្បៈរបស់ខ្លួន (បុរស៣៣ភាគរយ) និងស្ត្រី១៥ភាគរយមិនចង់បន្តជីវិតអាជីពជាសិល្បករអស់មួយជីវិតនោះទេ (បុរសមាន១០ភាគរយ)។

### ខ. អ្នកមានពិការភាពក្នុងសិល្បៈទស្សនីយភាព (គំនិតផ្តួចផ្តើមនិងការលើកទឹកចិត្តក្នុងសិល្បៈនៅមានការរើសអើង)

ដើម្បីផ្តល់នូវទិដ្ឋភាពទូទៅមួយអំពីអ្នកដែលមានពិការភាពក្នុងសង្គមខ្មែរ ការផ្តោតការសិក្សាទៅក្រុមអ្នកមានពិការភាពក្នុងវិស័យសិល្បករជាការសំខាន់មួយ។ សិល្បករ៨ភាគរយនិងធុរជន៦ភាគរយ ដែលកំពុងមានអាជីពក្នុងវិស័យនេះ គឺជាអ្នកដែលមានពិការភាព។ គួរបញ្ជាក់ផងដែរថាសម្រាប់ពួកគេភាគច្រើន ពិការភាពសំដៅទៅលើពិការភាពផ្នែករាងកាយ។ ក្រុមពិការភាពនេះភាគច្រើនជាបុរស (ចំនួន៨៦ភាគរយ) ដែលមានអាយុជាមធ្យម២៧ឆ្នាំ។

២៦. *សមភាពយេនឌ័រក្នុងទីផ្សារការងារនៃប្រទេសកម្ពុជា ធនាគារអភិវឌ្ឍអាស៊ី ចេញផ្សាយឆ្នាំ២០១៣*
២៧. *សន្ទង់ការងារពលកម្មនិងការងារកុមារឆ្នាំ២០១២ អង្គការពលកម្មអន្តរជាតិ ចេញផ្សាយឆ្នាំ២០១២*

៣៣ភាគរយនៃក្រុមពិការភាពនេះ មកពីអង្គការហ្វារពន្លឺសិល្បៈ និង៣៣ភាគរយទៀតមកពីអង្គការអេពិកអាត ដែលជាអង្គការសហគមន៍ប្រើសិល្បៈជាមធ្យោបាយមួយក្នុងការបង្កើតឲ្យមានការយល់ដឹងពីបញ្ហាផ្សេងៗក្នុងពិការភាពនិងការស្វែងរកការទទួលស្គាល់នូវលទ្ធភាពទោះបីជាមានពិការភាព។ ៨៦ភាគរយនៃក្រុមនេះ នៅកំពុងហាត់រៀនសិល្បៈ។ ៦៧ភាគរយហាត់រៀនសិល្បៈរៀងរាល់ថ្ងៃ និង៤៦ភាគរយហាត់រៀនយ៉ាងតិចម្តងក្នុងមួយសប្តាហ៍។ ស្ថានភាពនៃការបណ្តុះបណ្តាលសិល្បៈក្នុងក្រុមពិការភាពនេះមានសភាពដូចគ្នាទៅនឹងស្ថានភាពទូទៅនៃការបណ្តុះបណ្តាលសិល្បៈជាទូទៅក្នុងវិស័យនេះផងដែរ ។

ចំពោះសកម្មភាពសម្តែង យើងមិនបានទទួលនូវចម្លើយគ្រប់គ្រាន់ដែលអាចនាំឲ្យយើងអាចគណនានិងសន្និតនូវលទ្ធផលនៃប្រាក់ចំណូលរបស់ពួកគេបានទេ។ ប៉ុន្តែ យើងអាចនិយាយបានថាពួកគេមានការសម្តែងចំនួន៤៤ដងក្នុងឆ្នាំ២០១៣ ដែលជាបរិមាណមួយតិចជាងមធ្យមភាគទូទៅនៃចំនួនការសម្តែង។ គួរកត់សម្គាល់ផងដែរថា ៤០ភាគរយនៃពួកគេសម្តែងនៅក្នុងរង្គសាល ភោជនីយដ្ឋាន និងសណ្ឋាគារ ដែលជាសក្ខីកម្មនៃការចូលរួមក្នុងសេដ្ឋកិច្ចនៃទីផ្សារការងារមួយ។ អត្រាភាគរយនៃអ្នកទទួលបានប្រាក់ចំណូលប្រចាំខែតិចជាង ១០០ដុល្លារអាមេរិច គឺមានចំនួន៤០ភាគរយធៀបទៅតិចជាងក្រុមសំណាកសិល្បករទាំងមូលក្នុងសន្ទង់នេះដែលមានអត្រា៥២ភាគរយ។ ចំណែកឯអត្រាភាគរយនៃអ្នកដែលទទួលបានប្រាក់ចំណូលប្រចាំខែច្រើនជាង៤០០ដុល្លារ មានចំនួន១៦ភាគរយ ខ្ពស់ជាងក្រុមសំណាកសិល្បករវិញដែលមានអត្រាតែ១០ភាគរយ។

សិល្បករដែលជាក្រុមពិការភាពនេះ ផ្តល់នូវចម្លើយអំពីការលំបាកក្នុងការងាររបស់ខ្លួនដោយសារតែពិការភាព ដែលផ្តល់នូវឧបសគ្គមួយចំនួនក្នុងការងារ។ ការប្រាស្រ័យទាក់ទងគឺបញ្ហាប្រឈមដ៏ធំមួយ ហើយមានអ្នកពិការភាពមួយចំនួនបានប្រាប់អំពីបញ្ហានៃកង្វះការគោរពនិងបញ្ហានៃការរើសអើង។ ពួកគេក៏បានបញ្ជាក់ថាមានការលំបាកក្នុងការធ្វើដំណើរទៅធ្វើការសម្តែងផងដែរ។

### ការរើសអើងចំពោះអ្នកដែលមានពិការភាព

បញ្ហាក្នុងទំនាក់ទំនងរវាងអ្នកដែលមាននិងគ្មានពិការភាព បាននាំឲ្យអង្គការអេពិកអាតក្លាយជាគំរូសកម្មភាពការងារក្នុងសិល្បៈមួយ ដែលអង្គការនេះបានមានបេសកកម្មការងារលើកកម្ពស់ការយល់ដឹងអំពីពិការភាពដើម្បីលប់បំបាត់ការរើសអើង និងបង្កើននូវការចូលរួមកាន់តែធំជាងមុនក្នុងវឌ្ឍនភាពនៃវិស័យសិល្បៈទស្សនីយភាព ។

## គ. ស្ថានភាពទីតាំងភូមិសាស្រ្ត (សក្តានុពលខ្ពស់នៃទីក្រុង)

បើពិនិត្យមើលទៅលើទីតាំងភូមិសាស្រ្ត យើងសង្កេតឃើញថាអ្នករស់នៅក្នុងនិងក្បែរទីក្រុង រកប្រាក់ចំណូលក្នុងសិល្បៈបានច្រើនជាងអ្នកដែលមានទីលំនៅនៅទីតាំងដ៏ទៃផ្សេងទៀត។ ដូចមានបង្ហាញក្នុងតួលេខទី២៩ ស្ថានភាពទូទៅរបស់ទីក្រុងភ្នំពេញនិងសៀមរាបមានលក្ខណៈស្រដៀងខ្លាំងដែលសិល្បករ៥៥ភាគរយអាចរកចំណូលបានក្រោម១០០ដុល្លារអាមេរិច។ ក្នុងខេត្តកណ្តាលនិងខេត្តតាកែវ ដែលនៅក្បែរទីក្រុងភ្នំពេញ សិល្បករប្រមាណ៥០ភាគរយ រកចំណូលបានក្រោម១០០ដុល្លារអាមេរិចដែរ។ រីឯខេត្តកំពតនិងកំពង់ចាម យើងឃើញថា ខេត្តទាំងនេះ មានចម្ងាយឆ្ងាយពីទីក្រុង។ យើងវិភាគស្ថានភាពទីលំនៅដែលឆ្ងាយ (ចម្ងាយ អប្បបរមា៥០គីឡូម៉ែត្រ) ពីទីក្រុង (ក្រុងភ្នំពេញ ក្រុងសៀមរាប និងក្រុងបាត់ដំបងជាដើម) ប្រាក់កំរៃម៉ោងជាមធ្យមគឺមានចំនួន៥,៦ដុល្លារអាមេរិច (សម្រាប់ការសម្តែង) បើធៀបទៅគឺតិចជាងទីក្រុងដែលកំរៃមធ្យមនេះ គឺ៧,៤ដុល្លារអាមេរិច។ អ្នកដែលមានទីលំនៅឆ្ងាយពីទីក្រុង ប្រមាណ៧៣ភាគរយរកចំណូលបានក្រោម១០០ដុល្លារអាមេរិចក្នុងមួយខែ (សូមមើលផែនទីលេខ២) ។

**អ្នកដែលមានទីលំនៅឆ្ងាយពីទីក្រុង (ចម្ងាយអប្បបរមា ៥០គីឡូម៉ែត្រ) រកប្រាក់កំរៃម៉ោងជាមធ្យម បានចំនួន៥,៦ដុល្លារអាមេរិច (សម្រាប់ការសម្តែង) បើធៀបទៅគឺតិចជាងកំរៃមធ្យមក្នុងទីក្រុងដែលមានចំនួន ៧,៤ដុល្លារអាមេរិច**

### តួលេខទី២៩៖ ទិន្នន័យប្រាក់ចំណូលបែងចែកតាមខេត្ត ក្រុង ឆ្នាំ២០១៣



## ផែនទីលេខ២៖ ប្រាក់កំរៃបានមកពីការសម្ដែងដោយយោងតាមទីតាំងភូមិសាស្ត្រ






# សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវជាជំហានមួយយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍវិស័យសិល្បៈទស្សនីយភាព។ ព័ត៌មានដែលទទួលបានមកជាចំណេះដឹងដ៏សំខាន់ដែលសិល្បករអាចរៀនសូត្រនិងទទួលដឹងនូវបញ្ហាផ្សេងៗដែលពួកគេត្រូវប្រឈមក្នុងអាជីពសិល្បៈ។ ទិដ្ឋភាពទូទៅក្នុងវិស័យនេះ ដែលមានបង្ហាញក្នុងលទ្ធផលនៃសន្ទង់ផ្តល់ឲ្យពួកគេនូវទុនក្នុងការរកដំណោះស្រាយរួមគ្នា តាមរយៈការជជែកពិភាក្សាផ្លាស់ប្តូរយោបល់ ដើម្បីបង្កើតនូវដំណោះស្រាយផ្សេងៗដែលអាចអនុវត្តបាន ក្នុងគោលដៅធ្វើឲ្យប្រសើរឡើងក្នុងវិស័យនេះទាំងថ្នាក់ជាតិនិងថ្នាក់តំបន់។

វិស័យសិល្បៈទស្សនីយភាពខ្មែរមានសមាសភាពភាគច្រើនជាយុវជនវ័យក្មេងជំនាន់ក្រោយ។ ដូចដែលយើងបានបរិយាយពីខាងដើម របបខ្មែរក្រហមបានបំផ្លិចបំផ្លាញដល់ឫសគល់នៃសង្គមខ្មែរ ជាពិសេសសិល្បៈ។ ការងារស្តារឡើងវិញនូវសិល្បៈវប្បធម៌ គឺជាដំណើរការកំពុងបន្ត ហើយក្រុមសំណាកសិល្បករនិងធុរជនក្នុងសន្ទង់នេះ គឺជាកម្លាំងចលករក្នុងការស្តារឡើងវិញនេះ។ សិល្បករទាំងឡាយគឺជាយុវជន ដែលកំពុងបន្តការហាត់រៀនផ្នែកសិល្បៈតាមរយៈការបណ្តុះបណ្តាលក្នុងថ្នាក់រៀងរាល់ថ្ងៃ ការប្រតិបត្តិសិល្បៈដោយខ្លួនឯង និងការប្រឹងប្រែងទទួលជំនាញបន្ថែមដើម្បីពង្រឹងខ្លួនឯងក្លាយជាសិល្បករអាជីព។ ដំណើរការនៃការធ្វើឲ្យរស់ឡើងវិញនៃសិល្បៈទស្សនីយភាពខ្មែរនេះ អាចកើតឡើងមកដល់ស្ថានភាពបែបនេះ ដោយសារការងារគួរឲ្យកត់សម្គាល់របស់អង្គការសមាគមក្រៅរដ្ឋាភិបាល និងធុរជនសិល្បៈដែលបានបំពេញនូវការងារធុរកិច្ចរបស់ពួកគេ ស្ថាបនាឡើងនូវមូលដ្ឋានរចនាសម្ព័ន្ធនិងគោលការណ៍ផ្សេងៗសម្រាប់សកម្មភាពការងារសិល្បៈអាចប្រតិបត្តិទៅបាន និងដើម្បីធ្វើឲ្យសិល្បៈក្លាយជាប្រតិបត្តិមួយមានលក្ខណៈអាជីពនិងប្រកបដោយចីរភាពផ្តល់នូវជីវភាពរស់នៅមួយសមរម្យ។

ការអភិវឌ្ឍនៃវិស័យនេះក្នុងពេលបច្ចុប្បន្នគឺតាមរយៈការបណ្តុះបណ្តាលសិល្បៈការយកចិត្តទុកដាក់នូវសន្ទុះចិត្តសិល្បៈរបស់សិល្បករ ការបង្ហាញឲ្យពួកគេបានយល់ដឹងពីទម្រង់សិល្បៈថ្មី និងផ្តល់នូវមធ្យោបាយដើម្បីពួកគេរីកចម្រើនក្នុងអាជីព។ ក្រៅពីនេះ ជំនាញមិនមែនសិល្បៈដ៏ទៃទៀត ដូចជាបច្ចេកវិទ្យាព័ត៌មានវិទ្យាភាសាបរទេសបច្ចេកទេសពន្លឺនិងសំឡេងអាចជំរុញសិល្បករតាមរយៈការរៀនសូត្របន្ថែមឲ្យក្លាយទៅជាជំនាញអាជីពដ៏ប្រសើរមួយដែលសិល្បករអាចប្រើប្រាស់ក្នុងជីវភាពការងារសិល្បៈរបស់ពួកគេ។

ក្នុងស្ថានភាពសេដ្ឋកិច្ចនៃវិស័យសិល្បៈទស្សនីយភាពសន្ទង់នេះបង្ហាញពីប្រាក់ចំណូលដែលមានភាពខ្ពស់ទាបជាងគ្នា ដោយសារទម្រង់សិល្បៈបណ្តាញទំនាក់ទំនង ទីតាំងភូមិសាស្ត្រ និងយេនឌ័រ។ ទិន្នន័យដែលទទួលបានទាំងនេះអាចក្លាយជាទុននៃការគិតគូរមួយដែលសិល្បករអាចយកទៅប្រើប្រាស់ក្នុងការចូលរួមស្ថាបនានូវគោលនយោបាយថ្នាក់ជាតិ ដែលអាចបង្កើតនូវសកម្មភាពសិល្បៈដ៏រស់រវើក និងកាត់បន្ថយតាមការដែលអាចធ្វើបាននូវការរើសអើងផ្សេងៗដែលសិល្បករបានជួបប្រទះ ដូចជាសិល្បករស្ត្រីនិងសិល្បករដែលមានពិការភាពជាដើម។

ទិន្នន័យសំខាន់មួយទៀតគឺសិល្បករដែលធ្វើការមិនពេញម៉ោងក្នុងសិល្បៈ ដើម្បីទុកពេលវេលារកការងារបំពេញប្រាក់កំរៃបន្ថែម។ ទិន្នន័យនេះអាចផ្តល់នូវគំនិតដល់សិល្បករ ដែលពួកគេអាចគិតវិជ្ជមាននិងធ្វើការងារបន្ថែមជាមធ្យោបាយជួយបង្កើតនូវស្ថានភាពរស់នៅមួយដែលមានស្ថិរភាព។

ចុងក្រោយបំផុត យើងអាចសង្កេតបានតាមរយៈតួលេខទាំងអស់នៅក្នុងសន្ទង់នេះជាសក្តានុពលនៃវិស័យសិល្បៈ ដែលជាសកម្មភាពសេដ្ឋកិច្ចដ៏សំខាន់។ ការផ្សាភ្ជាប់វិស័យសិល្បៈជាមួយនិងទីផ្សារសេដ្ឋកិច្ចផ្សេងទៀត (ដូចជាសណ្ឋាគារ ភោជនីយដ្ឋាន) និងការដាក់បញ្ចូលសក្តានុពលទាំងអស់នេះជាកត្តាគន្លឹះអាចចូលរួមបង្កើននូវកម្លាំងសេដ្ឋកិច្ចបច្ចុប្បន្ន និងនាំទៅរកឱកាសការងារថ្មីជាច្រើនសន្ធឹកសន្ធាប់សម្រាប់សិល្បករ។



# សេចក្ដីថ្លែងអំណរគុណ

សន្ទង់ត្រូវបានធ្វើឡើងដោយលោក Edouard Fouqueray ដែលបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកសង្គមវិទ្យា-នរវិទ្យា ឯកទេសខាងសេដ្ឋកិច្ចសង្គម។ មុនពេលមកកាន់ប្រទេសកម្ពុជា Edouard ធ្លាប់បានធ្វើការសិក្សាស្រាវជ្រាវអំពីស្ត្រីកសិករនៅ Burkina Faso។ បេសកកម្មរបស់គាត់ជាអ្នកស្ម័គ្រចិត្តជាមួយអង្គការសិល្បៈខ្មែរអមតៈ បានទទួលការគាំទ្រដោយអង្គការ Service Cooperation au Développement។

មានមនុស្សជាច្រើនបានចូលរួមក្នុងសន្ទង់នេះ។ សូមសម្ដែងនូវអំណរគុណចំពោះសិល្បករ និងធុរជនសិល្បៈទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃជួយឆ្លើយបំពេញកម្រងសំណួរនៃសន្ទង់នេះ។ ជាមួយគ្នាផងដែរ សូមថ្លែងអំណរគុណដល់ស្ថាប័ន អង្គការសមាគមទាំងឡាយដូចមានរាយនាមខាងក្រោម ដែលបានជួយសម្របសម្រួលឲ្យសិល្បកររបស់ខ្លួនបានចូលរួមក្នុងសន្ទង់នេះ៖

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នាយកដ្ឋានសិល្បៈទស្សនីយភាព មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ (ខេត្តកណ្ដាល ខេត្តកំពង់ចាម ខេត្តកំពត ខេត្តតាកែវ ខេត្តបាត់ដំបង និងរាជធានីភ្នំពេញ) សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាលាមធ្យមវិចិត្រសិល្បៈ។

អង្គការអម្រឹតាសិល្បៈ Chantiers-Ecole de Formation Professionnelle, Collectif Clowns d'ailleurs et d'ici, សាលាសិល្បៈចំរុះចំប៉ី អង្គការអេពិកអាត សមាគមវិចិត្រសិល្បៈ វិទ្យាស្ថានសិល្បៈខ្មែរ មជ្ឈមណ្ឌលអភិវឌ្ឍវប្បធម៌ខ្មែរ អង្គការគ្រួសារថ្មី សាលាសិល្បៈតូរ្យតន្ត្រី ក្រុមល្ខោនបាសាក់នាយប៉េងប៉ោះ អង្គការហ្វារពន្លឺសិល្បៈ សហគ្រាសសិល្បៈហ្វារ ក្រុមល្ខោនបាសាក់រស្មីសាមគ្គី សមាគមសិល្បៈសុវណ្ណភូមិ ថាយនីធូន្យ៍ សមាគមថ្លៃថ្នូរ និងផលិតកម្មវឌ្ឍនៈ។

ក្រៅពីនេះ សូមថ្លែងអំណរគុណដល់សិល្បករឯករាជ្យទាំងឡាយដែលបានចូលរួមក្នុងសន្ទង់នេះ។ សូមថ្លែងអំណរគុណជាពិសេសដល់លោក ឃួន ចន្ទរស្មី លោក ងួន វុទ្ធី កញ្ញា អុន សុខនី និងលោក យាន រស្មី ដែលបានជួយជាអ្នកបកប្រែ និងអ្នកសម្របសម្រួលក្នុងជំនួបប្រជុំផ្សេងៗនៃគម្រោងនេះ។

សូមថ្លែងអំណរគុណដល់ក្រុមការងាររបស់អង្គការសិល្បៈខ្មែរអមតៈ ដែលបានគាំទ្រគម្រោងនេះ ជាពិសេសចំពោះ លោក សុង សេង និងកញ្ញា Frances Rudgard សម្រាប់ការណែនាំផ្សេងៗក្នុងសន្ទង់នេះ កញ្ញា គន់ លក្ខិណា សម្រាប់ការជួយទំនាក់ទំនងជាមួយសិល្បករនិងអ្នកតំណាងក្នុងសិល្បៈ លោក តាំង ប៉ោឆាយ សម្រាប់ការជួយបញ្ចូលទិន្នន័យ Noah Halton និង Joe Schreiber សម្រាប់ការជួយពិនិត្យកែតម្រូវរបាយការណ៍សម្រេច និងកញ្ញា Marion Gommard សម្រាប់ការចាត់ចែងទូទៅក្នុងការរចនានិងទំនាក់ទំនង។ សូមថ្លែងអំណរគុណចុងក្រោយបំផុតចំពោះលោក ឈិន វ៉ាន់នឿន សម្រាប់ជំនួយការងារដ៏មានតម្លៃ និងការអត់ធ្មត់ក្នុងការងារនេះតាំងពីដើមរហូតដល់ចប់។



Designed by Graphic Roots: www.graphicroots.net










15th ANNIVERSARY

សិល្បៈខ្មែរអមតៈ

CAMBODIAN LIVING ARTS


## ការិយាល័យប្រទេសកម្ពុជា

អគារលេខ ១២៨-៩ មហាវិថីសម្ដេចសុធារស
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៩៨៦ ០៣២
info@cambodianlivingarts.org

## USA OFFICE

228 Park Ave S #49331
New York, NY 10003-1502,
USA
Ph. 508 748 0816
Fax. 508 748 1976



## PHOTOS BY

Chean Long
Dennis Drenner
AirAsia/Travel3Sixty
Aga Cebula
Steve Golden
Matthew Wakem
Anders Jiras